ព្រះបាទឡាត់យោសនាគ

# ហែម-ចៀវ

# វីរបុរសជាតិ

## ឯកសារប្រវត្តិសាស្ត្រ

ព្រះពោធិវ័ង្ស

**សូរ-ហាយ**

រៀបរៀងនិងពិនិត្យ

**គង់-សម្ភារ**

ការផ្សាយរបស់សារព័ត៌មានអង្គរបូរី

ព.ស.២៥៤៨

# សូមឧទ្ទិសចំពោះ

វីរបុរសខ្មែរទាំងអស់ ដែលបូជាជីវិត
ដើម្បីជាតិ សាសនា ឲ្យមានសេរីភាពឡើងវិញ !
ព្រះសង្ឃដែលទ្រង់សិល
ដល់មិត្តយុទ្ធជនដែលការពារសាធារណរដ្ឋខ្មែរ
និងមិត្តទុក៏តទាំងឡាយ...

N

រៀបរៀងតាមឯកសារ

របស់លោក ប៉ែន-យុត្តិ ចាងហ្វាងសារណត៍មានប្រជាជាតិ
តាមថេរដិកាព្រះសង្ឃចាស់ៗជាច្រើនអង្គ
លោក ប៊ុណ្ណ-ចន្ទម៉ុល
លោក ឈឹម-ស៊ុម អតីតសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់
ដែលបានរួមបាតុកម្មតវ៉ាឲ្យបារាំងលែង
អាចារ្យ ហែម-ចៀវ មកវិញ ។

# អារម្ភកថាបោះពុម្ពគ្រាទី៣

មិត្តអ្នកអានជាទីមេត្រី,

នៅពេលបោះពុម្ពលើកទី៣នេះ ខ្ញុំបាទបានយកទៅប្រគេន ព្រះពោធិវ័ង្ស សួរ-ហាយ ពិនិត្យនិងបន្ថែមខ្លះដែលខ្វះខាត ដើម្បីឲ្យឯកសារវីរបុរសជាតិមានភាពត្រឹមត្រូវឡើង ។ ព្រះពោធិវ័ង្ស សួរ-ហាយ ថ្វីបើជាប់កិច្ចការដ៏ច្រើនក៏ដោយ ព្រះអង្គពេញហឫទ័យជួយពិនិត្យសៀវភៅនេះ យ៉ាងរីករាយជាទីបំផុត ។ ព្រះអង្គមានថេរៈដីកាមកកាន់ខ្ញុំថា «លោកសរសេរល្អគួរសមហើយ តែមានខុសខ្លះ អាត្មាបានមើលម្តងហើយ ។ សូមលោកខិតខំស្រាវជ្រាវប្រវត្តិវីរបុរសជាតិទៀតចុះ ចាំអាត្មាជួយពិនិត្យបើអាត្មាមានលទ្ធភាព...» ព្រះថេរៈដីកានេះធ្វើឲ្យចិត្តខ្ញុំរំភើបពេកក្រៃ ស្រមៃនឹកឃើញដល់ជនខ្លះ ដែលតែងតែដើរពេបជ្រាយដល់ស្នាដៃដ៏មានខ្លឹមសារនេះ ។ ខ្ញុំស្តាយណាស់ ស្តាយដោយជនទាំងនុ៎ះមិនព្រមផ្ញើសេចក្តីកែតម្រូវឬរិះគន់តាមបែបអ្នកចេះដឹងសោះ គេលេងតែស្នៀតពាលសាមាន្យលួចប្លន់ខ្ញុំទៅវិញ ។ សូមមិត្តអ្នកអានជួយពិចារណាមើលផងចុះ ! តើប៉ុន្មានសតវត្សរ៍ទៀតទើបគេបោះបង់គំនិតអប្រិយនេះចោល ?

ណ្ហើយខ្ជិលគិត យើងគិតតែវីរបុរសអាចារ្យ ហែម-ចៀវ ដែលជានិមិត្តរូបនៃវីរបុរសខ្មែរទាំងអស់បានហើយ ។

ខ្ញុំមានចិត្តរំភើបពន់ពេកណាស់ នៅពេលដែលរដ្ឋាភិបាលលើកឋានៈលោកជាវីរបុរសជាតិទី១ នៃសម័យអាណានិគមបារាំង ថ្វីបើខ្លួនខ្ញុំបានប្រគេនឋានៈនេះដល់ព្រះអាចារ្យមុនក៏ដោយ ។

ខ្ញុំមានជំនឿយ៉ាងមាំថា ជនណាក៏ដោយឲ្យតែចេះដឹងនឹកគុណូបការនៃបុព្វបុរស មុខជាមិនសាបសូន្យឡើយ ។

ជាទីអវសាន ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យសូមបារមីព្រះអង្គជួយទាញព្រលឹងខ្មែរណា ដែលកំពុងវង្វេងដោយតណ្ហាក្តី ទ្រព្យសម្បត្តិក្តី មនោគមវិជ្ជាក្តី ឲ្យវិលមកក្នុងសង្គមខ្មែរភ្ញាក់រលឹកតែមួយវិញ ដើម្បីកសាងប្រទេសតាមមាគ៌ាវីរបុរស ក្រឡាហោមគង់, អាចារ្យហែម-ចៀវ, អៀវ-កើស ។ល។ និង ។ល។ ឡើងវិញ ។

សូមបងប្អូនរួមឈាមដែលកំពុងរងទុក្ខវេទនាដោយសារសង្គ្រាមគ្រប់បែបយ៉ាង ឲ្យបានជួបតែសុខៈតរៀងទៅ ។

ភ្នំពេញថ្ងៃ ១០ កក្កដា ១៩៧២
អ្នករៀបរៀង

# ជម្រាបអ្នកអាន !

ពេលនេះក៏ដូចជាពេលមុនដែរ,

ប្រទេសខ្មែរយើងត្រូវពួកអាណានិគមបារាំងសេស ជិះជាន់ត្រួតត្រាមួយសត-វត្ស គឺពីឆ្នាំ១៨៦៣មកដល់១៩៥៣ ទើបមហាជនយើងរលាស់នឹមដ៏ចង្រៃនុ៎ះចោលចេញបាន ។ តើខ្មែរយើងសុខចិត្តដេកឲ្យបារាំងត្រួតត្រាទាំងអស់គ្នាដោយគ្មានការតស៊ូប្រយុទ្ធតបវិញឬ ?

យើងបានដឹងមកហើយតាមរយៈសៀវភៅ បណ្ដាំក្រឡាហោមគង់ ថាខ្មែរយើងមិនមែនធ្មេចភ្នែកឲ្យបរទេសសង្កត់សង្កិនទៅតាមអំពើចិត្តទេ គឺមានតែស្ដេចខ្លះនិងមន្ត្រីខ្លះទេ ដែលច្រើនតែជឿគោរពឱនក្បាលឲ្យបារាំងជាន់ ដើម្បីឲ្យខ្លួនគេបាននៅហុតឈាមប្រជារាស្ត្រខ្មែរតទៅទៀត ។

ទឹកភ្នែកដែលស្រក់អំពីការប្រមូលចងក្រង ប្រវត្តិនិងសកម្មភាពនៃវីរបុរសខ្មែរនេះ គឺជាសក្ខីភាពរបស់យុវជនស្រោចស្រង់ជាតិ ដែលកំពុងប្រយុទ្ធគ្រប់បែបយ៉ាងប្រឆាំងនឹងពួកយៀកកុង, មន្ត្រីធំៗស្អុយរលួយ និងរំលឹកឡើងវិញនូវអតីតកាលដ៏ឈឺចាប់ចុកឈាម ។

គ.ស.១៨៦៤ ប្រទេសខ្មែរត្រូវធ្វើសន្ធិសញ្ញាជាមួយប្រទេសបារាំង ដោយយកគេជាអាណាព្យាបាល ។

លុះមកដល់ឆ្នាំ១៨៨៤ ខ្មែរត្រូវធ្លាក់ក្នុងអនុសញ្ញារបស់បារាំងសេស ដែលមានស្ដេចនរោត្តម ជាអ្នកចុះហត្ថលេខាដាក់ប្រទេសខ្មែរទៅក្រោមអាណានិគមនិយមបារាំងសេស ។

ពីឆ្នាំ១៨៦៤មកដល់១៩៤២ វីរបុរសអាចារ្យស្វា, ពោធិកំបោរ, អាចារ្យលាក់, ស៊ីវត្ថា, ក្រឡាហោមគង់, ពិស្ណុលោកឈ្មូក ព្រមមួយអន្លើដោយប្រជារាស្ត្ររួមផង បានធ្វើការតស៊ូយ៉ាងស្វិតស្វាញ ដើម្បីដណ្ដើមយកប្រទេសរបស់ខ្លួនមកវិញ ។ តែត្រូវពួកស្ដេចខ្សិបខ្សៀវនឹងបារាំង ឲ្យសម្លាប់វីរបុរសស្នេហាជាតិយើងអស់ជាច្រើន ។ ម្ល៉ោះហើយសេចក្ដីរាងចាលបន្តិចម្ដងៗ ក៏ទៅពួនសម្ងំក្នុងបេះដូងខ្មែរឲ្យភ័យខ្លាចក្រែងមានគ្រោះថ្នាក់បាត់បង់ជីវិតដូចអ្នកមុនៗទៀត ។ ការធ្លាក់ចុះនៃប្រទេសយើងប្រៀបបាននឹងស្លឹកឈើជ្រុះចាកមែក ដោយសារអក្សរសាស្ត្រជាតិ ត្រូវបារាំងហាមមិនឲ្យកូនខ្មែររៀន គេឲ្យរៀនតែអក្សរសាស្ត្ររបស់គេ ប្រើប្រាស់សម្ភារៈប្រទេសគេចាប់តាំងពីសំលៀកបំពាក់ឡើងទៅ ។ ម្ល៉ោះហើយខួរក្បាលខ្មែរ ត្រូវវិលវល់លែងមើលឃើញរបស់ខ្លួនជាដាច់ខាត ។ ម្នាក់ៗដែលបានធ្វើការរាជការ ឬតែអួតសរសើរភាសាបារាំង ខ្ពើមភាសាជាតិឯង ស្អប់ម៉ែឯងដែលពិសារស្លា ស្លៀកសំពត់ចងក្បិន

ស្រឡាញ់ម៉ែគេដែលលាបក្រែម ជក់បារី ស្លៀកសំពត់ខ្វះក្រណាត់ទៅវិញ ! ត្រង់ហ្នឹងហើយជាមូលហេតុធ្វើឲ្យខ្មែរល្ងង់ខ្លួនហៅលែងឮ ! មើលលែងយល់ !

ការពិតដែលធ្វើឲ្យប្រជារាស្ត្រចុកឈាមនោះ គឺរឿងអក្សរសាស្ត្រយើងតែម្តង។ ប្រទេសបានឯករាជ្យជិតម្ភៃឆ្នាំនេះ ខ្មែរយើងពុំទាន់ឃើញកសាងបានអ្វីជាគោលចរិកសំរាប់ប្រជាជាតិសោះ ឃើញតែលើកតម្កើងភាសាបារាំងលើសពីបារាំងនៅត្រួតត្រាខ្មែរត្រីភាគ ។ បើយើងគិតឲ្យដល់ទៅ មនុស្សធ្លាប់ខ្ញុំគេ គំនិតវានៅតែខ្ញុំគេដដែល មិនព្រមលើកដម្កើងខ្លួនឯងឲ្យស្មើនឹងជាតិគេសោះ ។ ការប្រើភាសាបរទេសជាផ្លូវការដូច្នេះហើយ ធ្វើឲ្យអ្នករដ្ឋការនិងប្រជារាស្ត្រមានភាពដាច់ស្រយាលពីគ្នា ។ ដរាបណាមនុស្សទាំងពីរប្រភេទគ្មានភាពជិតស្និទ្ធនឹងគ្នា ដរាបនោះដំណើរកសាងសាធារណរដ្ឋយើង មុខជាមិនបានសំរេចសុភមង្គលទៀតហើយ ។

អាស្រ័យមូលដ្ឋានហ្នឹងហើយ ដែលធ្វើឲ្យបេះដូងព្រះអាចារ្យ ហែម-ចៀវ ខំប្រឹងប្រែងទេសនាពន្យល់ពុទ្ធបរិស័ទល្ងង់ខ្លៅ ក្រីក្រ លង់ស្មារតី ឲ្យក្រោកឈរឡើងកសាងជីវិតដោយខ្លួនឯង កុំដេកផ្សងសំណាងទៅតាមយថាកម្ម ។ លោកខិតខំធ្វើការដោយគ្មានគិតពេលវេលានិងជីវិតបង់ ព្រោះលោកពុំអាចរស់នៅក្រោមអំណាចពួកបរទេសកើត ។

ដូច្នេះកូនសៀវភៅដ៏តូចនេះ គ្មានបំណងអ្វីក្រៅពីចង់ឲ្យពលរដ្ឋខ្មែរ ដែលមិនទាន់បានស្គាល់លោកគ្រូអាចារ្យ ហែម-ចៀវ ឲ្យស្គាល់តែប៉ុណ្ណោះទេ ។

ខ្ញុំសូមគោរពវិញ្ញាណក្ខន្ធ និងអនុវត្តតាមអស់លោកវិរបុរសទាំងអស់ ដោយពេញចិត្តជាទីបំផុត ។

មោងឫស្សី, ថ្ងៃទី១០ មេសា ១៩៧១

**គង់~សម្ភារ**

**សាធារណរដ្ឋប្រជាធិបតេយ្យនិយម**

# ទឹកចិត្ត
## ព្រះអាចារ្យហែម_ចៀវ

ឆ្នាំងបាយលោកសង្ឃគឺនៅនឹងប្រជាជន បើប្រជាជនវេទនា, អត់បាយ, ប្រជាជនគ្មានសិទ្ធិសេរីភាព, បើប្រជាជននៅក្នុងឋានៈជាខ្ញុំកញ្ជះគេ លោកសង្ឃក៏ទទួលអំណោយផលអាក្រក់ដែរ ។ ដូច្នេះលោកសង្ឃដែលមានភារៈ ប្រោសសត្វលោក គឺត្រូវស្ដីប្រដៅធ្វើឲ្យមនុស្សមានស៊ី មានស្លៀក មានសេរីភាព ក្នុងប្រទេសឯករាជ្យ និងសន្តិភាពដ៏បរិបូណ៌ ។

★ ទឹកភ្នែកប្រជារាស្ត្រ គឺទឹកភ្នែកព្រះសង្ឃ ★

( ស្រង់ចេញពីសារពត៌មានប្រជាជាតិ )

## កថាទីមួយ
# ជីវប្រវត្តិនៃលោកគ្រូព្រះបាឡាត់ ហែម-ចៀវ

មុននឹងសិក្សាពីគោលគំនិតនៃវីរបុរសនីមួយៗ ជាបឋមយើងត្រូវសិក្សាអំពីជីវប្រវត្តិសង្ខេបរបស់ពាក្យសិន ។ ក្នុងពេលនេះ យើងនាំគ្នាសិក្សាអំពីជីវប្រវត្តិលោកគ្រូអាចារ្យ ហែម-ចៀវ ដែលជាមហាថេរមួយអង្គក្រឡេកឃើញប្រជារាស្ត្រ ទទួលទុក្ខទោសតាមឋានៈខ្លួនជាមនុស្សក្នុងអាណានិគម ហើយក្នុងសម័យនោះ (ឆ្នាំ១៩-៣៣-១៩៤២) គេបានលើកលោកជាវីរបុរសមួយដ៏ឆ្នើមក្នុងផ្លូវនយោបាយ រហូតមកដល់សព្វថ្ងៃ ។ តើលោកបដិសន្ធិក្នុងត្រកូលបែបណា ? ក្នុងទីណា ?

លោកគ្រូអាចារ្យ ហែម-ចៀវ ប្រសូត្រថ្ងៃអង្គារ ឆ្នាំច ព.ស.២៤៤០ គ.ស.១៨-៩៨ នៅភូមិអូរកូនទេញ (កោណ្ឌញ្ញ) សង្កាត់ដំបូកមានលក្សណ៍ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ (នៅខាងជើងជិតស្ពានស្ពាន់និយរថភ្លើងបាត់ដឹង) ។

ឪពុកលោកឈ្មោះ **ហែម** ធ្វើជាមេស្រុកដំបូកមានលក្សណ៍ ។ ម្ដាយលោកឈ្មោះឧបាសិកា **ឯម** ខំប្រឹងប្រែងធ្វើស្រែចម្ការដោយឥតខ្លាចហត់នឿយ ។ គ្រួសារនេះមានបងប្អូន៥នាក់គឺ ហែម-លី, ហែម-ចៀវ, ហែម-ហួត, នាងហែម-សុច, ហែម-សាយ ។ បងប្រុសលោកឈ្មោះ ហែម-លី ធ្វើជាស្មាក្តី (មេធាវី) ក្រោយមកធ្វើជាមេស្រុកតពីឪពុក ។

កាលនៅពីកុមារ លោកបានស្គាល់នូវសេចក្ដីលំបាកគ្រប់បែបយ៉ាង ដូចជាកូនកសិករក្រីក្រទូទៅដែរ គឺលោកបានឃ្វាលគោ រកអុស ដេញចាប តាមឋានៈនៃកូនកសិករជាមួយឪពុកម្ដាយព្រឹកល្ងាចរហូតដល់អាយុ១២ឆ្នាំ ទើបមេស្រុក ហែម ជាឪពុកនាំយកទៅប្រគេនព្រះសង្ឃសត្ថា **ជួន-ណាត** វត្តឧណ្ណាលោមក្រុងភ្នំពេញ ដោយហេតុមេស្រុក ហែម និងព្រះគ្រូសង្ឃសត្ថាជាមិត្តភក្តិនឹងគ្នាយ៉ាងជិតស្និទ្ធ ។

កុមារ ហែម-ចៀវ ជាក្មេងមានសីលធម៌ល្អប្លែកជាងក្មេងដទៃទៀតៗ មានមាត់ពាក្យរហ័សច្បាស់លាស់ មានសណ្ដាប់ធ្នាប់សមរម្យគួរឲ្យអ្នកផងពេញចិត្ត ។ កុមារនេះមានព្យាយាមខ្ជាប់ខ្ជួនល្អណាស់ បានរៀនអក្សរសាស្ត្រក្នុងសំណាក់ព្រះគ្រូសង្ឃសត្ថាតាំងអំពីដំបូង រហូតទាល់តែមើលបាន សរសេរអក្សរកើតដោយបរិបូណ៌ ។

កុមារ ហែម-ចៀវ បាននៅសិក្សាអប់រំក្នុងសំណាក់ព្រះគ្រូសង្ឃសត្ថា ជួន-ណាត អស់យូរឆ្នាំដោយបានដើរស្ពាយយាមព្រះគ្រូសង្ឃសត្ថា ដែលត្រូវនិមន្តទៅទេសនាក្នុងស្រុកខេត្តឯទៀតៗជាញឹកញយ ។ កុមារ ហែម-ចៀវ បានស្ដាប់ធម៌ទេ

សនារបស់ព្រះគ្រូសង្ឃសត្ថាអស់ច្រើនឆ្នាំ ទើបជាហេតុនាំឲ្យកុមារ ចៀវ មានសេចក្ដីឆ្លៀវឆ្លាស យល់ហេតុផលក្នុងផ្លូវលោកផ្លូវធម៌ជាច្រើនយ៉ាងណាស់ ជាកុមារមានសំដីវោហារព្រោកប្រាជ្ញពូកែជាងកុមារឯទៀតៗទាំងអស់ ។ កុដិដែលកុមារស្នាក់សិក្សា ស្ថិតនៅខាងក្រោយមហាកុដិសព្វថ្ងៃនេះ ។

កុមារ ហែម-ចៀវ ព្យាយាមរៀនសូត្រឥតធ្វេសប្រហែសឬខ្ជិលច្រអូសទេ ។ កុមារខំរៀនមិនថាយប់មិនថាថ្ងៃ ព្រោះលោកចាំបណ្ដាំបិតាក្នុងកាលដែលឪពុកនាំយកទៅទុកក្នុងសំណាក់នៃព្រះគ្រូសង្ឃសត្ថាថា ៖

- ចៀវ កូនប្រុសសំឡាញ់ឪពុក ៗគ្មានអ្វីចែកឲ្យកូនទេ គឺមានតែវិជ្ជានេះហើយដែលឯងអាចយឹតយោងគ្រួសារយើងឲ្យខ្ពង់ខ្ពស់បាន ។ មនុស្សល្ងង់គេមើលងាយណាស់កូន ! បើកូនចេះឪពុកក៏ចេះដែរ ! កូននៅភ្នំពេញខំរៀនឡើង ! កុំឈ្លោះប្រកែកគ្នាណា ! ខុសត្រូវម្ដេចម្ដាត្រូវចេះអត់ធ្មត់ទើបប្រសើរ ព្រោះយើងជាកូនកំសត់ដើរស្វែងរកវិជ្ជាដូចគ្នា ។ ដូច្នេះត្រូវចេះស្រឡាញ់គ្នា ទើបអ្នកផងសរសើរ ចូរកូនចាំសុភាសិតបុរាណមួយឃ្លាថា «នៅផ្ទះម្ដាយទីទៃ ទៅព្រៃម្ដាយជាមួយ» ។ លោកគ្រូព្រះសង្ឃសត្ថាអង្គនេះ ជាអ្នកប្រាជ្ញជ្រៅជ្រះ បានជាអញនាំកូនឯងមកឲ្យនៅនឹងលោក ត្រូវកូនឯងខំរៀនសូធ្យយកចិត្តទុកដាក់ឲ្យមែនទែន ។

- បាទលោកឪពុក កូននឹងគោរពតាមសំដីពុកលុះថ្ងៃស្លាប់ ! សូមពុកកុំព្រួយបារម្ភឲ្យសោះ !

- ល្អហើយកូនប្រុសឪពុក ! ឯងជាតំណាឈាមរបស់អញហើយ... អញសង្ឃឹមលើឯងគ្រប់ដប់ !

- ពាក្យនេះធ្វើឲ្យកុមារ ចៀវ ចងចាំទុកក្នុងបេះដូងឥតមានថ្ងៃភ្លេច ។ កុមារស្រឡាញ់គោរពតាមឱវាទមាតាបិតាណាស់ មិនដែលធ្វើឲ្យអ្នកមានគុណាព្រួយចិត្តម្ដងណាឡើយ ។

❑ ❑

❑

## កថាទីពីរ

# សាងផ្នួស

វ័យ១៦ឆ្នាំក៏ចូលមកដល់ លោកមេស្រុកហែមនិងភរិយាបានជំនុំគ្នា អំពីការបំបួសកូនជាសាមណេរ ហើយមូលមតិថាត្រូវបំបួសនៅវត្តឧណ្ណាលោម ហើយឲ្យគង់សំណាក់សិក្សាបរិបត្តិធម៌នៅវត្តឧណ្ណាលោមដដែល ។ លុះបួសរួចហើយ សាមណេរចៀវទន្ទេញមេសូត្រ (មូលវេយ្យាករណ៍បាលី) ចាំយ៉ាងស្ទាត់ជំនាញ ។

ថ្ងៃខែចេះតែកន្លងជាលំដាប់...

សាមណេរ ហែម-ចៀវ អាយុបាន២០ឆ្នាំ ក៏បំពេញឧបសម្បទា ជាភិក្ខុភាវៈក្នុងពុទ្ធសីមានៅវត្តលង្កា ដែលមានព្រះមហាវិមលធម្ម ថោង (ចាងហ្វាងសាលាបាលីជាន់ខ្ពស់មុនដំបូង) ជាឧបជ្ឈាយ មានព្រះគ្រូបវរវិជ្ជា ល្វី-ឯម និងព្រះគ្រូសង្ឃសត្ថា ជួន-ណាត ជាគ្រូសូត្រ ។ នៅពេលបំពេញជាភិក្ខុហើយ លោកក៏បានប្រឡងចូលរៀនសាលាបាលីជាន់ខ្ពស់ជាប់ដូចចិត្តប្រាថ្នា ។ ការសិក្សាចំនួន៧ឆ្នាំនៅសាលាបាលីជាន់ខ្ពស់ ធ្វើឲ្យលោកចេះដឹងផ្លូវលោក ផ្លូវធម៌ ល្មមប្រើការបានដោយពេញបរិបូណ៌ក្នុងផ្លូវព្រះពុទ្ធសាសនា ។ លោកជាសិស្សសំណប់មួយរូប នៃព្រះគ្រូសង្ឃសត្ថាជួន-ណាត ដែលលោកស្រឡាញ់ជាងគេ ដោយភិក្ខុហែម-ចៀវជាបព្វជិត ឈ្លាសវៃ រហ័សរហួន ចេះគួរសមទៅតាមឋានៈជាមនុស្សដូចគ្នា ។ លុះគំរប់ឆ្នាំទី៧ លោកបានប្រឡងយកសញ្ញាប័ត្រឱប្លូមសាលាបាលីជាន់ខ្ពស់ជាប់លេខ៦ ខាងភាសាបាលីដែលសម័យនោះ ខ្មែរយើងកំពុងរាប់អានណាស់ ។

នៅពេលប្រឡងចេញពីសាលាបាលីហើយ ក្នុងឆ្នាំ១៩២៧ កាលណោះលោករ៉េស្យម ជាតិបារាំង ធ្វើជារ៉េស៊ីដង់ខេត្តកំពត បានពឹងលើលោកមេគណវត្តអង្គសុរភីហៅកន្ទោ ស្រុកកំពង់ត្រាច ឲ្យជួយរកលោកសង្ឃមួយអង្គ ដែលមានសញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ ក្នុងកាលនោះលោកគ្រូមេគណវត្តកន្ទោនិមន្តមកឯវត្តឧណ្ណាលោមក្រុងភ្នំពេញ មកពឹងព្រះគ្រូសង្ឃសត្ថា ជួន-ណាត សូមនិមន្តលោកមួយអង្គដែលមានសញ្ញាប័ត្រឱប្លូមសាលាបាលីជាន់ខ្ពស់ ទៅបង្រៀនអក្សរសាស្ត្រខ្មែរនៅខេត្តកំពត ដោយហេតុលោករ៉េស៊ីដង់ រ៉េស្យម ខេត្តកំពតបង្កើតអង្គការសិក្សាអក្សរសាស្ត្រខ្មែរឲ្យមានរបៀបត្រឹមត្រូវឡើង ។

កាលនោះព្រះគ្រូសង្ឃសត្ថា បានចាត់លោកអាចារ្យ ហែម-ចៀវ ឲ្យទៅបង្រៀនអក្សរសាស្ត្រជាតិឯខេត្តកំពត យកវត្តក្រាំងដូងស្រុកបន្ទាយមាស និងវត្តកន្ទោស្រុកកំពង់ត្រាចជាមជ្ឈមណ្ឌល ។ គ្រូអាចារ្យ ហែម-ចៀវ បានទៅនៅបង្រៀនអក្សរសា

ស្រុកជាតិក្នុងខេត្តកំពតអស់៦ឆ្នាំ គឺតាំងពីឆ្នាំ១៩២៧ដល់១៩៣២ ទើបត្រឡប់មកនៅភ្នំពេញវិញ រួចបានប្រឡងជាប់ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ក្នុងឆ្នាំនោះឯង ។

ក្រៅពីម៉ោងបង្រៀនសិស្ស លោកអាចារ្យតែងនិមន្តទៅទេសនាជាញឹកញយ ។ ទេសន៍កន្លែងណាក៏ដូចកន្លែងណាដែរ លោកច្រើនតែយកពុទ្ធភាសិតថា វីរយេន ទុក្ខរច្ចេតិ ហើយនិង អត្តា ហិ អត្តនោ នាថោ មកអធិប្បាយពន្យល់លើកឧទាហរណ៍ដើម្បីឲ្យពុទ្ធបរិស័ទងាយស្តាប់បាន ។

❑ ❑

❑

# លក្ខណៈខ្លះដែលគួរដឹង

លោកគ្រូអាចារ្យ ហែម-ចៀវ មានសម្លេងធំក្រអួន មានទឹកដមគួរឲ្យចង់ស្តាប់ហើយស្តាប់ទៀត, មានរោមហាក្បោះក្បាយរអិលទៅមុខជាដរាប ពុំមានខ្លួនពាក្យដដែលៗ សូម្បីតែមួយម៉ាត់ក៏គ្មានដែរ ។ ប៉ុន្តែលោកពុំសូវពូកែខាងសរសេរសៀវភៅទេ ព្រោះសម្បូរណ៍ពាក្យពេចន៍និងរវល់បង្រៀនទេសនាពេក ។

ចំណែកដំណើរទេសនាចេញបែបដូចគ្រូរបស់លោកបេះបិត គឺសម្តេចព្រះសង្ឃរាជ ជួន-ណាត (តាមប្រសាសន៍របស់លោក ឈឹម-ស៊ុម) ។ ត្រង់នេះបានសេចក្តីថា លោកគ្រូព្រះបាទឡាត់ឃោសនានាគ ហែម-ចៀវ មានលក្ខណ:មិនខុសពីសម្តេចព្រះសង្ឃរាជប៉ុន្មានទេ ។

ចំពោះភ្ញៀវពន្លឺលោកទទួលដោយរាក់ទាក់ ឥតរើសមុខថាអ្នកមានអ្នកក្រអ្វីទេ ។ ជនណាដែលបានប្រាស្រ័យជាមួយលោកម្តងហើយ ជននោះរនែងចង់ប្រាស្រ័យម្តងទៀត ដើម្បីស្តាប់លោកអធិប្បាយញែកវែក អំពីទ្រឹស្តីព្រះពុទ្ធដែលដឹកនាំសត្វលោកឲ្យដល់ត្រើយនៃសុភមង្គល ។

រីឯការបង្រៀនសិស្សវិញ ពូកែពន្យល់ខាងចេះធ្វើឲ្យសិស្សចូលចិត្តរៀនណាស់ សូម្បីតែសាស្រ្តាចារ្យនៅសាលាបាលីជាន់ខ្ពស់ ក៏មិនអាចអត់ទ្រាំសរសើរលោកបានដែរ ។

សិស្សរបស់លោកស្រឡាញ់លោកគ្រប់ៗគ្នា ព្រោះជាសាស្រ្តាចារ្យមិនប្រកាន់ធម៌អគតិ ។ បើឃើញសិស្សណាខ្ជិលរៀនសូត្រ លោកតែងពោលចំពោះសិស្សនោះដោយសម្លេងថ្នមៗ ៖

- ចូរលោកខំរៀនឡើង ! កុំបណ្តែតបណ្តោយព្រោះយើងជាភេទដែលអ្នកផងគេគោរពរាប់អាន គេធ្វើទាន... ម៉ែឪយើងនៅក្រោមការត្រួតត្រារបស់បរទេស ព្រះពុទ្ធសាសនាត្រូវចុះអន់ថយជាលំដាប់ អក្សរសាស្រ្តយើងស្ទើរសាបសូន្យទៅហើយ គួរយើងប្រឹងប្រែងកុំខ្លាចនឿយហត់ ដើម្បីស្រោចស្រង់មាតុភូមិឲ្យរួចពីខ្ញុំកញ្ជះបារាំង កុំភ្លេចខ្លួនឲ្យសោះថា យើងជាអ្នកបួសរស់ដោយសារប្រជាជនចិញ្ចឹម ត្រូវតែមានចំណេះវិជ្ជាជ្រៅជ្រះ ទើបធ្វើឲ្យអ្នកចិញ្ចឹមយើងមានសទ្ធាជ្រះថ្លា ។ ចុះបើយើងល្ងង់ខ្លៅ តើដឹកនាំគេម្តេចកើត ? តើនរណាគេគោរពរាប់អានយើង ? បញ្ហានេះសូមលោកគិតពិចារណាមើលឲ្យមែនទែន បំណាច់យើងចោលស្រុកចោលស្រែចម្ការ ម៉ែឪបងប្អូនមករៀននៅទីនេះ។ តើយើងមកដើម្បីអ្វី ? យើងសុទ្ធតែកូនអ្នកក្រដូចគ្នាត្រូវ

ជួយគ្នាឡើង កុំធ្វេសប្រហែសឲ្យសោះ ប្រយ័ត្នគេមើលងាយណា៎ ខ្ញុំគ្មានអ្វីជួយលោកទេ មានតែចំណេះវិជ្ជាដ៏ស្តួចស្តើងប៉ុណ្ណោះ ។ លោក ! ការដែលខ្ញុំនិយាយនេះមិនមែនជាការប្រៀនប្រដៅទេ គឺជាការរំលឹកគ្នាទៅវិញទៅមក ក្នុងឋានៈជាកូនអ្នកស្រែនិងអ្នកបួសដូចគ្នា យើងត្រូវតែណែនាំគ្នាដើម្បីស្វែងរកសុភមង្គលឲ្យប្រទេសយើងដែលបានបាត់បង់ច្រើនឆ្នាំមកហើយ...។

ពាក្យដាស់តឿនរបស់លោកគ្រូបាឡាត់ឃោសនាគ ហែម-ចៀវ ធ្វើឲ្យសិស្សសាលាបាលីជាន់ខ្ពស់ស្រឡាញ់គ្រូ ហើយខិតខំរៀនសូត្រឥតហ៊ានធ្វេសប្រហែសសោះឡើយ ។ មិនត្រឹមតែស្រឡាញ់ ខំរៀនប៉ុណ្ណោះទេ ថែមទាំងមានការឈឺចាប់នឹងពួកអាណានិគមបារាំងខ្លាំងឡើងៗជាលំដាប់ ធ្វើឲ្យមជ្ឈដ្ឋានអ្នកស្នេហាជាតិកោតសរសើរសិស្សសាលាបាលីជាន់ខ្ពស់គ្រប់ៗគ្នា ។

ក្នុងពេលនោះហើយ ដែលធ្វើឲ្យកិត្តិនាមរបស់លោកគ្រូព្រះបាឡាត់ហែម-ចៀវក្រអូបគ្រប់ទិសទី ។ ស្រុកណាភូមិណាខេត្តណា ក៏ចង់និមន្តលោកទៅសំដែងធម៌ទេសនាដែរ ម្ល៉ោះហើយលោកមានពេលសំរាកតិចណាស់ ។

❑ ❑

❑

## កថាទីបី

# សកម្មភាពដើម្បីជាតិសាសនា

លុះចប់កិច្ចសិក្សាហើយ លោកបានទៅធ្វើជាគ្រូបង្រៀនអក្សរសាស្ត្រជាតិនៅវត្តក្រាំដូង បង្រៀនព្រះសង្ឃសំរាប់ធ្វើគ្រូ តទៅ ប្រកបទៅដោយជោគជ័យជាទីបំផុត ។

ក្រៅពីពេលបង្រៀន លោកឆ្លៀតសិក្សាខ្លួនឯងទៀត ដើម្បីឈោងចាប់យកសេចក្ដីពិតមកទូន្មានខ្លួននិងសិស្សានុសិស្ស ព្រមជាមួយអន្លើដោយឧបាសក ឧបាសិកាដែលត្រូវការចង់ចេះចង់ដឹង ។

នៅពេលលោកទេសនាមាត់ទទេលើកដំបូង មិនសូវមានអ្នកស្ដាប់ច្រើនប៉ុន្មានទេ ព្រោះខ្មែរជាន់ដើមទម្លាប់តែទេសន៍តាមសាស្ត្រាស្លឹករឹត ។ ម្ល៉ោះហើយចាស់ៗខ្លះប្រកាន់ថា «ធម៌សម័យថ្មីគេមិនចេះស្ដាប់ទេ» ។ ហេតុការណ៍ទាំងនេះពុំបានធ្វើឲ្យលោកគ្រូអាចារ្យ ហែម-ចៀវ ព្រួយបារម្ភលំបាកចិត្តអ្វីទេ ដោយលោកឈ្លាសវៃក្នុងការពន្យល់មុនដំបូងវាតែងមានប្រតិកម្មដូច្នេះហើយ បើយើងមិនតស៊ូទេ មុខជាមិនបានសំរេចបំណងឡើយ ។ ចាប់តាំងពីពេលនោះមក ព្រះអាចារ្យតែងធ្វើសេចក្ដីស្និទ្ធស្នាលចំពោះចាស់ៗណាដែលមិនសូវចូលចិត្តស្ដាប់លោកសម្ដែងធម៌មាត់ទទេ ជាងអ្នកផងទាំងពួង ។ មិនយូរប៉ុន្មានអ្នកទាំងនោះក៏ស្ដាប់បាន ងាយយល់ ថែមទាំងសម្លេងពិរោះផង ហើយស្រឡាញ់លោកហួសនិយាយ ចង់ឲ្យតែលោកអាចារ្យសំដែងធម៌ទេសនារាល់ថ្ងៃសីលនិងបុណ្យទាន ។ នៅឆ្នាំនោះហើយដែលព្រះសង្ឃខ្មែរយើង ចាប់ប្រែសូត្រមន្តពីភាសាបាលីមកជាភាសាខ្មែរ ។ កាប្រែមកឲ្យស្ដាប់បាននេះ ធ្វើឲ្យអ្នកគិតមិនដល់ជេរត្មះតិះដៀលដល់ព្រះសង្ឃដែលខិតខំប្រែយ៉ាងសំបើមរហូតដល់មានប្ដឹងផ្ដល់ទៅចូលតុលាការថែមទៀត ។

ប៉ុន្តែសេចក្ដីតស៊ូប្រឹងប្រែងធ្វើការ ដើម្បីឲ្យសាសនាបានរុងរឿងមានប្រយោជន៍ដល់មហាជន ដោយមិនតបតទៅតាមអំពើពាលល្ងង់ខ្លៅ កិច្ចការនោះក៏បានសំរេចជោគជ័យជាស្ថាពរ រហូតមកដល់សព្វថ្ងៃនេះ ។

មកដល់ភ្នំពេញ លោញអាចារ្យ ហែម-ចៀវ បានទទួលថាន:ជាអាចារ្យសាលាបាលីជាន់ខ្ពស់ (សាស្ត្រាចារ្យ) មានកំរៃប្រចាំខែ៥០រៀល ល្មមនឹងទ្រទ្រង់ជីវភាពឲ្យសំរេចទៅកើត ។

លោកគ្រូអាចារ្យ ហែម-ចៀវ មានសាមណសក្តិជាព្រះបាឡាត់ឃោសនាគរបស់សម្ដេចព្រះសង្ឃរាជ ជួន-ណាត កាលលោកនៅជាព្រះពុទ្ឍឃោសាចារ្យ មុខងារ

ថ្វីនេះពុំអាចទាញកម្លាំងចិត្តស្នេហាជាតិរបស់លោកឲ្យភ្លេចបានឡើយ ។ លោករឹងរឹតតែខំរៀន ខំអានសៀវភៅខ្មែរបរទេសដែលសំខាន់ៗស្ដីអំពីរឿងសាសនា នយោបាយ សេដ្ឋកិច្ច អក្សរសាស្ត្រ ទស្សនវិជ្ជាគ្រប់ទិវារាត្រី ឥតបីបណ្ដោយឲ្យពេលវេលាកន្លងផុតដោយពុំបានធ្វើអ្វីជាប្រយោជន៍ទេ ។ ក្រៅពីការសិក្សាបង្រៀនសិស្សទេសនា ពន្យល់ខ្មែរល្ងិតល្ងង់ ព្រះបាឡាត់ឃោសនាគ ហែម-ចៀវ ឆ្លៀតពេលទៅប្រាស្រ័យទាក់ទងនឹងវរជនធំៗដែលស្នេហាមាតុភូមិជាច្រើនទៀត ដូចជាលោកប៉ាចឈឺន, សឺង-ង៉ុកថាញ់, ជុំ-មួង, នួន-ដួង និងស៊ឹម-វ៉ា ។ល។ ដើម្បីរិះរកមធ្យោបាយរំដោះជាតិឲ្យរួចពីខ្ញុំបារាំង ។

វេលាថ្ងៃមួយ លោកសឺង-ង៉ុកថាញ់ បានទៅជួបព្រះបាឡាត់ ហែម-ចៀវ ហើយប្រគេនដំណឹង ៖

- លោកគ្រូព្រះបាឡាត់បំណងយើងជិតបានសំរេចហើយ !

- ពរ ! ជិតបានសំរេចអីលោក ?

ព្រះបាឡាត់ ហែម-ចៀវ ចោទសំណួរដោយងឿងឆ្ងល់ ។

លោកសឺង-ង៉ុកថាញ់ញញឹមបន្តិចរួចបន្លឺវាចា ៖

- ករុណាម្ចាស់ សព្វថ្ងៃនេះ ដូចជាលោកគ្រូអាចារ្យដឹងស្រាប់ហើយ ទាហានជើងក្រហមនិងជើងខ្មៅមិនត្រូវគ្នាទេ ដោយសារបារាំងចេះតែចាក់រុកឲ្យបែកសាមគ្គី ។ ឥឡូវនេះបារាំងបានចាត់ឲ្យខ្ញុំករុណា និមន្តព្រះសង្ឃទេសនាពន្យល់ពួកទាហានទាំងនុ៎ះ, ដើម្បីកុំឲ្យទាស់គ្នាទៀត ។ ក្នុងពេលនេះ ខ្ញុំករុណាសូមនិមន្តលោកអាចារ្យហើយ ។

- ឃើ ! ម៉េចក៏លោកមិននិមន្តលោកអាចារ្យ ប៉ាង-ខាត, សូ-ហាយ ផង ?

- ករុណា ខ្ញុំនិមន្តតែទាំងអស់អង្គហ្នឹង មិនឲ្យសល់ទេ តែធ្វើយ៉ាងណាកុំឲ្យពួកវាដឹងឬសង្ស័យ ក្រែងទៅទេសនាឬពន្យល់ទៀត ។

- ពរ ការនេះមិនថ្វីទេចំពោះរូបអាត្មាភាព តែអាត្មាព្រួយក្រែងខ្មែរយើងខ្លះចង់បានបុណ្យសក្តិពីបារាំង ហើយយកការណ៍ទៅឲ្យបារាំងវិញ !

- ករុណាវាពិតហើយ តែយើងមិនត្រូវខ្លាចទេ ។ យើងត្រូវខំពុះពារគ្រប់ឧបសគ្គ ទើបបំណងរបស់យើងបានសំរេច ។

- ពរត្រូវហើយលោក ! អាត្មាមិនដែលនឹកខ្លាចដល់គ្រោះថ្នាក់អ្វីផ្ទាល់ខ្លួនទេ គឺខ្លាចបែកការសម្ងាត់របស់ក្រុមបដិវត្តន៍យើង ! អាត្មាមិនមែនជាអ្នកនយោបាយដូចលោកទេ គឺជាអ្នកបួស គ្រាន់តែទេសនាពន្យល់ពុទ្ធបរិស័ទឲ្យស្គាល់ ឲ្យដឹង ឲ្យយល់ ឲ្យអនុវត្តតាមព្រះសម្ពុទ្ធទេតើ ! បើស្លាប់ដើម្បីជាតិ សាសនា អាត្មាក៏មិនតូចចិត្តដែរ ធ្វើម្ដេចវាសនាមនុស្សវាត្រូវទទួលដូច្នេះ !

- ត្រូវហើយលោកគ្រូម្ចាស់ ការពិតដែលយើងត្រូវនិយាយនោះ យើងត្រូវតែនិយាយឲ្យប្រជារាស្ត្រដឹង ។ លេងធម៌និយមអែបអប មុខជារាស្ត្រលិចលង់ដដែល ។ ខ្ញុំករុណាសុខចិត្តបូជាជីវិតជូនជាតិ សាសនា អស់ហើយ ពុំមានខ្លាចស្លាប់ទេ ! ព្រោះយើងកើតមករមែងស្លាប់ទៅវិញជាធម្មតា ។ ខ្ញុំករុណាគិតសុំថ្វាយបង្គំលាសិនហើយ !

- កុំប្រញាប់អញ្ជើញពេកលោក !

- ខ្ញុំករុណាមានការច្រើនទៀតដែលត្រូវធ្វើ ! ចាំថ្ងៃក្រោយ ចាំជជែកឲ្យយូរបន្តិច ។

- ពរអញ្ជើញចុះលោក សូមឲ្យបានសុខ !

លោកសឹង-ង៉ុកថាញ់ក៏ក្រាបបង្គំលាព្រះអាចារ្យ វិលទៅលំនៅវិញប្រកបដោយទឹកចិត្តរីករាយជាអនេក ។

ក្រុមខ្មែរអ្នកភ្ញាក់រលឹក ចេះតែដើរឃោសនាបញ្ចុះបញ្ចូលរាស្ត្រ ព្រះសង្ឃ គ្រប់និគមជនបទឲ្យមានការឈឺចាប់ឡើង ។ លោកប៉ាច-ឈឺន មាននាមល្បីខ្ទរខ្ទារដោយធ្វើជាចាងហ្វាងសារពត៌មាន «នគរវត្ត» មានអ្នកអានសុទ្ធជាអ្នកស្រឡាញ់ជាតិពិតប្រាកដ ។ ប្រជារាស្ត្រនិងព្រះសង្ឃ បានគាំទ្រសារពត៌មាននេះយ៉ាងពេញទំហឹង ។

ចំណែកខាងព្រះសង្ឃ ដែលខំតស៊ូយ៉ាងស្វិតស្វាញមិនខ្លាចស្លាប់ដើម្បីមាតុភូមិរស់នោះគឺ លោកអាចារ្យប៉ាង-ខាត់ សាស្ត្រាចារ្យភាសាសំស្ក្រឹត, លោកគ្រូអាចារ្យសួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក, លោកគ្រូអាចារ្យ ខៀវ-ជុំ គង់នៅវត្តលង្កា, ព្រះងាចារ្យ ហែម-ចៀវ សាស្ត្រាចារ្យភាសាបាលី និងសាមណសិស្សនៅសាលាបាលីជាន់ខ្ពស់ជាច្រើនអង្គទៀតជួយផង ។ ព្រះសង្ឃទាំងអង្គអស់នេះហើយ ដែលធ្វើឲ្យទាហានខ្មែរភ្ញាក់រលឹក លែងឈ្លោះទាស់ទែងគ្នាដោយខុសបទ ។ ក្រុមទាហានបារាំងកាចសាហាវណាស់ មិនស្គាល់ច្បាប់ទម្លាប់អ្វីសោះ ។ បងប្អូនខ្មែរយើងស្អប់ខ្ពើមមិនឲ្យកូនទេ ។ ដូច្នេះហើយ បានជាអ្នកស្រុកស្រែចម្ការហាមមិនឲ្យកូនធ្វើទាហានព្រោះខ្លាចគេស្អប់ រហូតដល់សព្វថ្ងៃ ។ ក្រុមទាហានទាំងនោះ ចូលទៅដល់ភូមិណាភូមិនោះមុខជាហិនហោចទ្រព្យសម្បត្តិមិនខាន ។ នេះជានយោបាយបំបែកបំបាក់ដើម្បីត្រួតត្រារបស់ចោរព្រៃបារាំង ។

គ.ស.១៩៤០ ។

កងទ័ពជប៉ុនក៏ចូលមកដល់ (សូមមើលគុកនយោបាយរបស់លោក ប៊ុណ្ណចន្ទ-ម៉ុល បើចង់ជ្រាបច្បាស់) ដើម្បីវាយកំចាត់សត្រូវរបស់ខ្លួនគឺបារាំង អាមេរិកាំង អង់គ្លេស នៅក្នុងឥណ្ឌូចិនទាំងមូល ។ ពេលនោះកងទ័ពបារាំង មានកម្លាំងខ្សោយណាស់ទៅហើយ ។ ខ្មែរយើងឃើញដូច្នេះ ក៏ចូលទៅទាក់ទងនឹងជប៉ុន ដើម្បីឲ្យគេជួយ

ពួកជប៉ុនក៏យល់ព្រមតាមសេចក្ដីស្នើរបស់លោកសឺង-ង៉ុកថាញ់ ដែលជាអ្នកតំណាងក្រុមបដិវត្តន៍ ។

នៅពេលទេសនាម្ដងៗ ព្រះអាចារ្យ ហែម-ចៀវ បានលើកយកពុទ្ធភាសិតខំខាន់ៗ ដែលទាក់ទងនឹងជីវភាពប្រជារាស្ត្រ ដើម្បីឲ្យជ្រាបច្បាស់ បានដឹងច្បាស់នូវគោលបំណាងនៃព្រះបរមគ្រូរបស់យើង ។ ពុទ្ធភាសិតទាំងនោះគឺ ៖

- ★ កុំធ្វើមនុស្សឲ្យចង្អៀតលោក ។
- ★ ត្រូវគិតបច្ចុប្បន្នឲ្យបានសុខជាមុន ព្រោះថាបើបានសុខក្នុងបច្ចុប្បន្នហើយ អនាគតមុខជាបានសុខទៀត ។
- ★ ត្រូវខំធ្វើការ កុំដេកផ្សងសំណាង ។
- ★ កន្លងសេចក្ដីទុក្ខបាន ព្រោះព្យាយាមខ្ជាប់ខ្ជួន ។
- ★ មានតែខ្លួនយើងទេ ដែលជាទីពំនឹងបាន ។
- ★ បុគ្គលមិនគប្បីសេពគប់នូវមិត្តដ៏លាមកទាំងឡាយឡើយ មិនគប្បីសេពគប់នូវបុរសដ៏ទាបថោកទាំងឡាយឡើយ គប្បីសេពគប់តែនឹងកល្យាមិត្តទាំងឡាយ គប្បីសេពគប់នូវបុរសដ៏ឧត្តមទាំងឡាយ (១០០គាថា) ។
- ★ មនុស្សឥតប្រាជ្ញា រមែងណែនាំនូវចំណែកដែលមិនគួរណែនាំ រមែងដឹកនាំឲ្យប្រកបក្នុងចំណែកដែលមិនជាធុរៈ ជាមនុស្សគឺគេណែនាំ ឬប្រដៅឲ្យបានល្អដោយលំបាក កាលបើគេនិយាយល្អៗ ក៏ស្រាប់តែច្រឡោតខឹង, មនុស្សនោះមិនចេះដឹងវិន័យច្បាប់អ្វីឡើយ, កិរិយាមិនជួបប្រទះ ឬមិនឃើញនូវមនុស្សដូចនោះ ជាការល្អ (១០០គាថា) ។
- ★ បុគ្គល មិនគួរអាស្រ័យអ្នកដទៃចិញ្ចឹមជីវិតឡើយ ។

ពុទ្ធភាសិតទាំងអស់នេះ លោកចង់ឲ្យប្រជារាស្ត្រមានសេរីភាព ដោយពឹងផ្អែកលើខ្លួនឯងជាមូលដ្ឋាន, កុំផ្ញើវាសនាទៅលើស្ដេច ដែលជាមនុស្សឃោរឃៅសប្បាយភ្លេចជាតិ នោះមិនល្អទេ ។ ក្រៅពីលើកពុទ្ធភាសិត លោកអាចារ្យបានទាញឧទាហរណ៍ល្អៗពីប្រទេសនានា ដែលគេចេះកសាងជាតិឲ្យបានរុងរឿងគ្រប់វិស័យ ។ មិនត្រឹមតែបណ្ដុះស្មារតីឲ្យខ្មែរក្រោកឈរប្រយុទ្ធយកឯករាជ្យពីបារាំងនោះទេ លោកបានបណ្ដុះស្មារតីកូនខ្មែរឲ្យស្រឡាញ់ការសិក្សា ឲ្យយល់តម្លៃនៃវិជ្ជាថែមទៀតផង ។

មហាវិស្សមកាលក៏ចូលមកដល់...

ព្រះអាចារ្យ ហែម-ចៀវ បាននិមន្តទៅវត្តកំណើត ដើម្បីសួរសុខទុកញោមញាតិ និងភិក្ខុសាមណេរឯទៀតដែលរាប់អានគ្នា ។ នៅពេលយប់ឡើង មានចាស់ៗស្រីប្រុស និងភិក្ខុសាមណេរបានមកចោមរោម ដើម្បីឲ្យលោកអធិប្បាយធម៌ឬរឿងរ៉ាវផ្សេងៗឲ្យស្ដាប់ ។ មុនដំបូង លោកលើករឿងអ្វីផ្សេងៗដែលមានប្រយោជន៍ ទើប

លោកមានថេរដីកាមួយៗ ៖

- ប្រទេសយើងមិនដឹងពេលណា រួចពីខ្ញុំបារាំងទេ ។ បារាំងមកត្រួតត្រាស្រុកយើង ហិនហោចទ្រព្យសម្បត្តិអស់ គ្មានអ្វីចំរើនរុងរឿងសោះ, ដូចយើងរាល់គ្នាឃើញស្រាប់ហើយ អាត្មាធ្វើបុណ្យរាល់ថ្ងៃ បួងសួងសុំឲ្យខ្មែរបានឯករាជ្យមកវិញ ដើម្បីកុំឲ្យបរទេសជិះជាន់យើងតទៅទៀត ។

ខណ:នោះលោកតាម្នាក់ពោលឡើង ៖

- ករុណាម្ចាស់ក៏គិតដូចលោកគ្រូអាចារ្យដែរ តែមិនដឹងធ្វើម៉េចបានឈ្នះពួកបារាំងទេ ។

ចំណុចនេះបានធ្វើឲ្យទឹកព្រះទ័យព្រះអាចារ្យរីករាយពេកក្រៃ ។ លោកក៏តបដោយសម្លេងក្រអួនព្រមទាំងញញឹមផង ៖

- ពរជាការងាយទេ លោករាបើយើងចង់បានឯករាជ្យ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញផ្លូវឲ្យយើងដើរ ហើយថា «សេចក្ដីសាមគ្គី នាំមកនូវសេចក្ដីសុខគ្រប់យ៉ាង» ។

តែកាលណាយើងស្រុះស្រួលគ្នា យើងនឹងអាចធ្វើអ្វីៗកើតមិនខាន ។ អាត្មាសង្ឃឹមថា បើប្រជារាស្ត្រយើងស្រុះស្រួលគ្នា មុខជាឈ្នះបារាំងពេលឆាប់ៗនេះមិនខាន ។ តែបើខ្មែរយើងមិនស្របគ្នាទេ យើងពុំអាចដណ្ដើមយកសេរីភាពនោះមកវិញបានឡើយ ។ អាត្មាមិនពេញចិត្តនឹងអ្នកខ្លះ ដែលគេយកព្រះពុទ្ធសាសនា ដើម្បីបំភិត្តមតិប្រជារាស្ត្រ ហើយបោកប្រជារាស្ត្រជាដាច់ខាត ។ លោកតា ! លោកទាំងអស់ឃើញស្រាប់ហើយ ប្រទេសយើងមានអ្នកបន្លំខ្លួន កេងយកកំរៃពីសាសនាសម្បើមណាស់ ។

- ករុណាម្ចាស់ ពិតហើយការនេះ !

ការសន្ទនាអំពីរឿងសាសនានយោបាយ និងអំពីការណែនាំឲ្យប្រជាជនចេះប្រកបការងារចិញ្ចឹមជីវិត ស្របតាមគន្លងព្រះសម្ពុទ្ធ បានប្រព្រឹត្តទៅរហូតពាក់កណ្ដាលអាធ្រាត្រទើបឈប់ ។

ពេលនិមន្តទៅស្រុកម្ដងៗ ព្រះអាចារ្យតែងនិមន្តគ្រប់ផ្ទះបងប្អូនណាដែលក្រីក្រជាងគេ ។ លោកពេញចិត្តប្រាស្រ័យជាមួយជនជំពូកនោះ ក៏ដូចជាលោកពេញចិត្តនឹងភូមិកំណើតឬព្រះសម្ពុទ្ធដែរ ។

❑ ❑

❑

## កថាទីបួន

# ព្រះបាទឡាត់ ហែម-ចៀវ ត្រូវបារាំងចាប់ផ្សឹក

ព្រះអាទិត្យជិតអស្តង្គតរលត់រស្មីទៅហើយ...

សម្លេងរៃយំគ្រលួច ពីលើចុងគគីរមកប៉ះត្រចៀកបុរីជន ឲ្យស្រងេះស្រងោចខ្លោចផ្សា ស្ទើរទប់ជលនេត្រពុំបាន ។

ឆ្នាំ១៩៤២ ជាឆ្នាំដែលប្រទេសយើងត្រូវបាត់បង់អ្នកស្នេហាជាតិមាតុភូមិអស់ជាច្រើន ។

ព្រឹត្តិការណ៍សកលលោក បានតឹងតែងជាលំដាប់ ។

សង្គ្រាមលោកលើកទី២ក៏ផ្ទុះឡើង ។

ស្ថានការណ៍ក្នុងប្រទេសខ្មែរ មានសភាពតឹងតែងស្ទើរកែលែងរួច ព្រោះប្រជាជនខ្មែរយើងហាក់ដូចជាលង់លក់ ដោយមិនដឹងថា ប្រទេសអញនៅក្រោមអំណាចរបស់បារាំងទេ ។ តែបើដឹងវិញ ក៏គ្រាន់តែត្រឹមដឹងស្ទើរ មិនហ៊ានធ្វើសកម្មភាពអ្វីឡើយ ។ តើដោយសារអ្វី ? ជនជាតិខ្មែរដែលបារាំងចាប់ខ្លួន គ្មានវរជនឬស្តេចណាទៅសុំតវ៉ាឲ្យរួចខ្លួនមកវិញទេ ។ គេបែរជាជំរុញឲ្យបរទេសសម្លាប់ចោលទៅវិញ ។ ម៉្លោះហើយ, អ្នកមានចំណេះតិចរមែងខ្លាចស្លាប់ជាធម្មតា ការភ័យខ្លាចក៏កើតមានឡើង ។

តែខ្មែរឈាមអង្គរវត្ត ធ្លាប់ធ្វើជាមហាអំណាចមួយនឹងគេដែរ ក៏ក្រោកឈរទាញដៃបងប្អូនឈាមខ្លួនឲ្យតស៊ូប្រយុទ្ធឡើង ។

ក្រុមបដិវត្តន៍បានតស៊ូធ្វើសកម្មភាពរបស់ខ្លួនយ៉ាងមមាញឹក ដើម្បីឲ្យទាន់ស្ថានការណ៍សកលលោកដែលកំពុងច្បាំងគ្នា ។ ពេលនោះព្រះអាចារ្យ ហែម-ចៀវ តែងនិមន្តទៅអប់រំខ្មែរស្រុកស្រែចំការជាញឹកញយ ដើម្បីសុំការឧបត្ថម្ភពីប្រជារាស្ត្រ គ្រប់មធ្យោបាយនិងគ្រប់សម្ភារៈ ។

ចំណែកប្រជារាស្ត្រនិងព្រះសង្ឃ បានគាំទ្រក្រុមបដិវត្តន៍ តាំងផ្លូវចិត្តផ្លូវកាយឥតសង្ស័យឡើយ ។

ផែនការសម្ងាត់របស់ខ្មែរបដិវត្តន៍ បានដឹងដល់ក្រសួងស៊ើបអង្កេតនៃពួកបរទេស ។ ការនេះដឹងដោយសារទាហានខ្មែរយើងដែលនៅស្រឡាញ់បារាំង ហើយយក

ការណ៍ទៅឲ្យបារាំងដើម្បីខ្លួនបានបុណ្យស័ក្តិ (១) ។

តាមសៀវភៅគុកនយោបាយរបស់លោកប៊ុណ្ណ-ចន្ទម៉ុល ដែលជាសមាជិកម្នាក់ដ៏សំខាន់នៃក្រុមបដិវត្តន៍ បានសរសេរយ៉ាងច្បាស់លាស់ថា ដោយពួកទាហានខ្មែរដែលបានមកទាក់ទងជាមួយលោកគ្រូអាចារ្យ ហែម-ចៀវ និងលោក នួន-ឌួង នោះ, មានទាហានខ្លះដែលស្រឡាញ់បារាំងដុះស្លែក្នុងខួរដុះមិនជ្រះនោះ, វានាំរឿងសម្ងាត់នេះទៅប្រាប់បារាំង ថាលោកអាចារ្យ ហែម-ចៀវ និងលោក នួន-ឌួង ជាមេដឹកនាំពួកទាហានខ្មែរឲ្យបះបោរប្រឆាំងនឹងបារាំង ។ ទាហានខ្មែរចំនួន១៥នាក់ ត្រូវចាប់ស្ងាត់ៗដើម្បីកុំឲ្យបែកការណ៍ ។

នៅថ្ងៃ១៧ កក្កដា ១៩៤២ ស្រាប់តែឃើញចាងហ្វាងគិញបារាំងម្នាក់ និងលេខាធិការខ្មែរពីរនាក់ទៀត មានកាន់សំណុំលិខិតមួយដុំផង, បានទៅជួបលោក អ៊ុំង-អ៊ី នាយករដ្ឋមន្ត្រី ព្រមទាំងលោក ទា-សាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងធម្មការនិងមន្ត្រីឯទៀត ។ គ្រានោះ លោក ទា-សាន បានបញ្ជាលោក ជុំ-មួង (កាលណោះធ្វើជាលេខាធិការក្រោមបង្គាប់លោក) ឲ្យទៅនិមន្តលោកគ្រូអាចារ្យ ហែម-ចៀវ មក ។ លោក ជុំ-មួង នឹកប្រហែលជាមានការធំហើយ ក្នុងរឿងសម្ងាត់ជាមួយគ្នា តែចាប់លោកគ្រូអាចារ្យ ហែម-ចៀវ ទៅនឹងរាលដាលដល់អាត្មាអញមិនខាន, ប៉ុន្តែពុំទាន់ដឹងច្បាស់ជារឿងអ្វីដែរ ? ដោយពុំហ៊ានសួរគេ ។

លោក ជុំ-មួង ក៏ទៅវត្តឧណ្ណាលោម និមន្តលោកគ្រូ ហែម-ចៀវ លោកក៏បាននិមន្តជាមួយគ្នាជាបន្ទាន់ ។ តាមផ្លូវ, លោកក៏បានសួរលោក ជុំ-មួង ពីដំណើរដែលលោករដ្ឋមន្ត្រីឲ្យមកនិមន្តនេះ ។ លោក ជុំ-មួង ក៏ទូលលោកតាមដំណើរដែលបានឃើញ តែពុំដឹងជារឿងអ្វី ។ លោកមានថេរដីកាថា ៖ បើវាសួរពីរឿងយើង យើងឆ្លើយប្រកែកថា តែពុំបានដឹងទៅ ! រួចលោកមានថេរដីកាតមកទៀតថា លោកសឹង-ង៉ុកថាញ់បានផ្ដាំថា បើបារាំងវាដឹងរឿង ត្រូវឲ្យប្រញាប់រត់ចូលទៅឯមន្ទីរកងអាវុធហត្ថជប៉ុនជាប្រញាប់ ទើបរួចខ្លួន ! យោបល់ទាំងពីរនាក់យល់ថា ច្បាស់ជាបារាំងវាដឹងរឿងសម្ងាត់ហើយ, ប៉ុន្តែពុំបានគិតដល់រឿងអ្វីទេ នឹកថាប្រហែលជាវាគ្រាន់តែហៅសួរសិនតែប៉ុណ្ណោះទេយ៉ាងមើល ?

លុះលោកគ្រូអាចារ្យ ហែម-ចៀវ ទៅដល់ ស្រាប់តែលោក ទា-សាន ប្រើឲ្យបំរើទៅទិញខោ១ អាវ១ មកហើយ បង្ខំលោកគ្រូអាចារ្យ ហែម-ចៀវ ឲ្យផ្លាស់ស្បង់ចីពរពីខ្លួន ហើយស្លៀកពាក់ខោអាវភ្លាមរួចបារាំងវានាំទៅតាមរថយន្តវាបាត់ទៅតែម្តង

------------

(១) មានចាស់ៗខ្លះបាននិយាយថា អាចារ្យ ហែម-ចៀវ ដែលត្រូវបារាំងចាប់នេះ មកពីស្ដេចសីហនុឱ្យបឲ្យបារាំងចាប់ ទើបបានជាពួកវាដឹង ។ ស្ដេចសីហនុ ខ្លាចក្រុមបដិវត្តន៍រំលាយរាជបល្លង្កចោល ទើបធ្វើដូច្នេះ ។

រកតែរត់ទៅប្រាប់អ្នកណាក៏មិនទាន់ ។ គិតទៅពួកគេចាប់លោកផ្សឹកទាំងឥតជំនុំសោះ ។

លោក ជុំ-មួង កាន់តែភ័យខ្លាំងថា អញច្បាស់ជាបារាំងវាចាប់ខ្លួនទៀតជាពុំខាន ។ លុះដល់ពេលចេញពីធ្វើការ ក៏ទៅជំរាបលោក សឺង-ង៉ុកថាញ់ តាមដំណើរ ។ លោកក៏ប្រាប់ថា ឲ្យប្រយ័ត្នខ្លួនឲ្យមែនទែន បារាំងប្រាកដជាចាប់យើងហើយ ។

រឿងចាប់លោកគ្រូអាចារ្យ ហែម-ចៀវ ក៏ផ្អើលឆោឡោឡើង ក្នុងបណ្ដាពួកលោកសង្ឃជានិស្សិតនៃសាលាបាលីជាន់ខ្ពស់ និងវត្តនានាក្នុងក្រុងភ្នំពេញ ដែលច្រើនតែជាមិត្តភក្តិនិងជាសិស្សរបស់លោក ។

ក្នុងពេលជាមួយគ្នានោះ លោក នួន-ឌួង ក៏ត្រូវគិញបារាំងទៅចាប់ឯផ្ទះដែរ ។

នៅពេលដែលបារាំងចាប់ផ្សឹក លោកគ្រូអាចារ្យ ហែម-ចៀវ មានការឈឺចាប់ឥតឧបមា ធ្វើឲ្យទឹកនេត្រាលោកហូរដោយមិនដឹងខ្លួន ។ លោកនឹកតូចចិត្តនឹងខ្មែរគ្នាឯង ដែលធ្វើធំហើយមិនជួយឈឺឆ្អាលការពារកិត្តិយសព្រះសង្ឃ, បែរជាបណ្ដោយឲ្យជនបរទេស ញាំញីតាមអំពើចិត្តរបស់គេ ។ លោកគ្មាននឹកខ្លាចថា បារាំងធ្វើទារុណកម្មអ្វីទេ តែលោកនឹកស្ដាយគំរោងការណ៍ ដែលនឹងជិតបានសំរេចផលផ្ដល់ទៅឲ្យប្រជារាស្ត្រខ្មែរ ដែលរស់ក្នុងអន្លង់ទុក្ខក្រោមក្រញាំបិសាចបារាំង និងស្ដេចយង់ឃ្នងជាច្រើនឆ្នាំមកហើយ ។

នៅក្នុងទីឃុំឃាំង លោកអាចារ្យ ហែម-ចៀវ អង្គុយសម្ងឹងតាមរន្ធតូចមួយ មើលទៅមេឃាដែលមានដុំពពករសាត់គ្រឿនៗ ប្រៀបដូចជាដុំទុក្ខផុសចេញពីក្រអៅបេះដូងនៃប្រជាជនរួមជាតិ ។ ព្រះអាចារ្យពោលតែម្នាក់ឯង ទាំងទឹកភ្នែកសស្រាក់ ៖

- ឱ ! ប្រទេសអញអើយ ! តើកាលណាទៅនឹងបានឯករាជ្យ សម្បូរសប្បាយដូចសម័យមហានគរវិញ ! បើមន្ត្រីធំៗសុទ្ធសឹងលក់ក្បាលយ៉ាងដាច់ថ្លៃ ឲ្យបារាំងទៅហើយ...។

- តើថ្ងៃណា ទើបខ្មែរយើងក្រោកពីដេក ? ទើបខ្មែរស្គាល់ខ្លួនឯងជាមនុស្សដូចសាសន៍ដទៃ !

- ឱ ! ប្រិយមិត្ត ! ដែលរួមថ្លើម ស៊ូប្ដូរជីវិតឥតស្ដាយស្រណោះ ដើម្បីស៊ូគ្រលាស់ខ្លួន ឲ្យរួចពីនឹមអាណានិគមបារាំងសែស ! មិត្តមិនដឹងជាព្រួយយ៉ាងណាទេ ! ព្រោះខ្លាចបែកការណ៍ (ផែនការសម្ងាត់) របស់យើង ! មិត្តអើយ ទោះបីអាចោរអបលក្សណ៍ទាំងនោះ យកអាវុធមកពុះទ្រូងរូងយកថ្លើមខ្ញុំក៏ដោយ ខ្ញុំមិនឆ្លើយប្រាប់នូវការណ៍ពិតទាំងនោះឡើយ ! ខ្ញុំមិនសុខចិត្តឲ្យប្រទេសខ្ញុំស្លាប់ជាដាច់ខាត ហើយខ្ញុំមិនសុខចិត្តរស់ដោយឃើញប្រទេសខ្ញុំកញ្ជះគេដែរ ។

ឱមិត្តរួមសាសនា ! ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវិញ្ញាណ

កូនចៅវីរបុរសខ្មែរ ដែលមានលោកក្រឡាហោមគង់ជាដើម ជួយគាំពារឲ្យការតស៊ូរបស់យើងបានសម្រេចជោគជ័យកុំបីខាន ដើម្បីឲ្យកូនចៅរបស់យើង ស្គាល់នូវសិទ្ធិ សេរីភាព យុត្តិធម៌ សុភមង្គល ដូចអារ្យប្រទេសនានា...។

ទំនួញដ៏សោកសៅនេះ បានហើរចូលទៅក្នុងបេះដូងខ្មែរអ្នកស្នេហាជាតិ ឲ្យរឹងរឹតតែក្លាហានឡើងជាទ្វេភាគ ។ សេចក្ដីទុក្ខលំបាករបស់លោក ដែលបារាំងបានធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ដើម្បីសួរចម្លើយនោះ មានវិសាលភាពមិនអាចពណ៌នាបានឡើយ ។

រីឯលោក នួន-ឌួង ធ្វើការនៅក្រុមជំនុំប្រែព្រះត្រៃបិដក ក៏ត្រូវទទួលអំពើយង់ឃ្នង ដូចព្រះអាចារ្យ ហែម-ចៀវ ដែរ តែវីរបុរសទាំងពីររូបនេះ បានរក្សាទុកកិត្តិយសខ្មែរយើងរហូតមកដល់សព្វថ្ងៃ ។

❑ ❑

❑

## កថាទីប្រាំ

# មហាបាតុកម្មថ្ងៃ២០ កក្កដា ១៩៤២

ដំណឹងបារាំងចាប់ផ្សឹកលោកគ្រូអាចារ្យ ហែម-ចៀវ បានធ្វើឲ្យសាមណសិស្ស នៅសាលាបាលីជាន់ខ្ពស់ រំជើបរំជួលយ៉ាងខ្លាំង ហើយផ្សាយទៅគ្រប់វត្តអារាមនិង ខេត្តក្រៅដើម្បីរួមប្រជុំគ្នា ធ្វើបាតុកម្មតវ៉ាឲ្យបារាំងដោះលែងលោកគ្រូអាចារ្យ ហែម ចៀវ និងលោក នួន-ឌួង ពីទីឃុំឃាំងមកវិញ ។

មហាបាតុកម្មនេះ បំរុងធ្វើនៅថ្ងៃទី១៨ កក្កដា តែត្រូវអាក់ខានទៅវិញ ដោយនៅ វត្តលង្កាជាប់រវល់ធ្វើបុណ្យចំរើនព្រះជន្មវស្សាព្រះធម្មលិខិត ល្វី-ឯម ជាចាងហ្វាង សាលាបាលីជាន់ខ្ពស់ ក្នុងឱកាសដែលលោកឡើងសមណស័ក្តិទីជាព្រះធម្មលិខិត ។ ពិធីបុណ្យនេះបានបង្ហើយនៅថ្ងៃទី១៩ កក្កដា ។

ពេលនោះ លោក សឺង-ង៉ុកថាញ់ បានភៀសខ្លួនទៅពួនឯការិយាល័យកងអា វុធហត្ថជប៉ុន ដើម្បីគេចខ្លួនឲ្យផុតពីកណ្តាប់ដៃបារាំងសែស ក្នុងគោលបំណងដឹក នាំក្រុមបដិវត្តន៍ក្នុងការរំដោះជាតិឲ្យបានសម្រេច ។

ការទាក់ទងរវាងលោក សឺង-ង៉ុកថាញ់ និងមេដឹកនាំខាងបាតុកម្ម បានប្រព្រឹត្ត ទៅយ៉ាងសកម្ម ដោយមានលោក ប៉ិណ្ឌ-ចន្ទម៉ុល ជាអ្នកនាំពាក្យ ទៅជម្រាបលោក ប៉ាច-ឈឺន ដែលជាបុរសម្នាក់មានចិត្តរឹងដូចថ្ម ។

រាត្រីថ្ងៃទី១៩កក្កដា មេដឹកនាំពួកបាតុករបានរៀបចំក្បួនដោយក្រុមៗ តាមកម្ម វិធីរបស់ខ្លួនជាស្រេច ។

ថ្ងៃទី២០ កក្កដា ក៏ចូលមកដល់...

ប្រជារាស្ត្រនិងព្រះសង្ឃខ្មែរ នៅទីក្រុងភ្នំពេញ ដៃកាន់ដងបដា ដើរសំដៅទៅ វិមានទេសាភិបាលបារាំង នៅខាងលិចវត្តភ្នំ (ទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការសព្វ ថ្ងៃ) ប្រកបដោយទឹកមុខអង់អាចក្លាហាននិងខឹងផង ។ នៅខាងលើផ្ទាំងបដានោះ មានចារិកពាក្យស្លោកថា «យើងខ្ញុំសូមឲ្យដោះលែងលោកគ្រូអាចារ្យ ហែម-ចៀវ និ ងលោក នួន-ឌួង មកវិញ» ។

ពួកបាតុករ បានទៅដល់ការិយាល័យទេសាភិបាលបារាំងយ៉ាងកុះករ ដោយចំ រុះដោយពណ៌លឿងផង ធ្វើឲ្យទិដ្ឋភាពនេះគួរគយគន់ឥតគណនា ។

នៅមុខពួកបាតុកររាប់ម៉ឺននាក់ គេក្រឡេកឃើញលោក ប៉ាច-ឈឺន ឈរយ៉ាង សង្ហា គ្មានព្រឺរោមខ្លាចពួកបារាំងយង់ឃ្នងធ្វើបាបអ្វីឡើយ ។ មុនដំបូងលោកប៉ាច-

ឈឺនបានវ៉ាយវ៉ាច់ប្រាប់បារាំងពីហេតុការណ៍ផ្សេងៗ និងសុំជួបទេសាភិបាលបារាំង តែបារាំងឲ្យចូលពីរបីនាក់ប៉ុណ្ណោះ ។ ក្រុមបាតុករមិនព្រមព្រោះខ្លាចពួកវាចាប់ទៀត ។ ពេលនោះដោយមនុស្សច្រាលចុះច្រាលឡើង ធ្វើឲ្យលោកប៉ាច-ឈឺនជ្រុលខ្លួនចូលក្នុងរបងការិយាល័យរបស់បរទេស ហើយបារាំងក៏បិទទ្វារ រួចវានាំមេបាតុករតាមផ្លូវក្រោយបាត់ទៅ ។

ឃើញបារាំងចាប់លោកប៉ាច-ឈឺនដូច្នេះ ក្រុមបាតុករទ្រាំមិនបាន ក៏បះគិលវាយគិញបារាំង យួនបែកក្បាលហូរឈាមឡើង ។ ព្រះសង្ឃដេញចាប់បារាំងនឹងដងឆ័ត្រ ព្រោះតែខឹងគេធ្វើបាបសាស្ត្រាចារ្យរបស់ខ្លួន ។ ចំណែកគ្រហស្ថប្រើដុំថ្ម ដំបងនិងកូនតឹងជាអាវុធដែរ ។

ការបះបោរវាយដូច្នេះ ធ្វើឲ្យខូចគំរោងការអស់រលីង ដែលលោកសឺង-ង៉ុកថាញ់បានទាក់ទងឲ្យជប៉ុនជួយធ្វើអន្តរាគមន៍ បើប្រសិនណាទេសាភិបាលបារាំងមិនដោះលែងវីរជនទាំងពីរទេ (សូមអានគុកនយោបាយរបស់លោក ប៉ុណ្ណ-ចន្ទម៉ុល)

ពេលកំពុងវាយប្រឡុកគ្នានោះ ពួកបារាំងបានថតរូបបាតុករ ដើម្បីស្រួលដើរចាប់ ។ ព្រះភិក្ខុ ប៉ាង-ខាត់ និងព្រះអាចារ្យ អ៊ុក-ជា, លោកប៉ុណ្ណ-ចន្ទម៉ុល, លោកជុំ-មួង, ភិក្ខុធម្មបាល ខៀវ-ជុំ ។ល។ បានរត់គេចខ្លួនយ៉ាងរហ័ស ។ ជនណាយឺតដំណើរក៏ត្រូវពួកបារាំងចាប់ដាក់គុកអស់ ។

ព្រះតេជព្រះគុណ ប៉ាង-ខាត់ គេចខ្លួនរួច ហើយបែរជានិមន្តទៅឲ្យបារាំងចាប់ដោយចិត្តក្លាហានជាទីបំផុត ។ លោកប៉ុណ្ណ-ចន្ទម៉ុលក៏ត្រូវបារាំងចាប់ដែរ ។

រីឯព្រះអាចារ្យ អ៊ុក-ជា និងភិក្ខុធម្មបាល ខៀវ-ជុំ បាននិមន្តភៀសខ្លួនទៅកាន់ប្រទេសសៀមទាំងទឹកភ្នែក ។ (ព្រះអាចារ្យ អ៊ុក-ជា គង់នៅស្រុកសៀមរហូតមកដល់សព្វថ្ងៃ) ។

ចំណែកលោក ជុំ-មួង ក៏បានគេចខ្លួនទៅបាត់ដំបងដែរ ។

ខ្មែរអ្នកស្នេហាជាតិ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ដែលចាប់បាន គេដាក់ក្នុងទីឃុំឃាំង រួចបញ្ជូនទៅគុកធំភ្នំពេញទុកកាត់ទោស ។

ចំណែកស្តេចសីហនុ គ្មានគិតបញ្ហាប្រទេសជាតិទេ គឺគិតតែសប្បាយនឹងស្រីញី រាំវែក ពេញចន្ទឆាយា ពុំជួយឈឺឆ្អាលពួកបាតុករសោះ ដែលជាចូលដៃនឹងបារាំងជេរព្រះសង្ឃថា «អាត្រងោលបួសបំផ្លាញបាយ» ទៅវិញ ហើយថែមទាំងហាមមិនឲ្យសិស្សសាលាបាលីជាន់ខ្ពស់ប្រើឆ័ត្រដងដែកទៀតផង ។ (លោកតាម្នាក់មានប្រសាសន៍ថា ស្តេចសុរាម្រិតបានដឹកប្រាក់សុទ្ធនិងមាសទៅសូកបារាំងច្រើនណាស់ ដើម្បីឲ្យកូនខ្លួនបានសោយរាជ្យ ។ បារាំងក៏យល់ព្រមហើយដាក់ខសន្យាកុំឲ្យសីហនុភ្លេចបារាំង ។ ដូច្នេះហើយបានជាស្តេចសីហនុនឹកគុណបារាំងមិនភ្លេច ។

បាតុកម្មនេះពុំបានសំរេចដូចគោលបំណងទេ គឺហាក់ដូចជាគ្រាន់តែធ្វើឲ្យជាការសាកល្បង ឲ្យខ្មែរទូទៅដឹងខ្លួនប៉ុណ្ណោះ ។

ក្រោយមកអ្នកទោសនយោបាយ ក៏ត្រូវបារាំងបញ្ជូនទៅព្រៃនគរតាមកប៉ាល់ដើម្បីកាត់ទោស ។

❑ ❑

❑

## កថាទីប្រាំមួយ

# ការកាត់ទោសប្រហារជីវិត

នាវាស្រែកលាកំពង់ផែភ្នំពេញបីវូម ក៏ទម្លាក់កន្ទុយហើយធ្វើដំណើរគ្រឿនៗទៅ ។

នៅលើនាវា លោកគ្រូអាចារ្យ ហែម-ចៀវ, លោកប៉ាច-ឈឺន, លោក នួន-ឌួង និងអ្នកទោសឯទៀតជើងជាប់ច្រវាក់ សម្លឹងមើលកំពូលវត្តឧណ្ណាលោម សម្តែងនូវសេចក្តីអាលោះអាល័យមាតុភូមិ មិនចង់ឃ្លាតឆ្ងាយទេ លោកស្តាយខានបានរស់នៅជាមួយជនរួមឈាមជាទីស្នេហា ! ស្តាយខានឃើញមុខឧបាសកឧបាសិកា ដែលតែងពិគ្រោះគ្នាអំពីបញ្ហាជាតិ-សាសនា ។ លោកអាចារ្យកំសត់លើកដៃទាំងពីរប្រណមហើយពោលខ្សឹបៗ ៖

- ខ្ញុំម្ចាស់សូមថ្វាយព្រះបង្គំលាហើយ មិនដឹងថ្ងៃណាបានជួបវិញទេ ! សូមព្រះបារមីជួយថែរក្សាទូលព្រះបង្គំផង ទូលបង្គំចង់រស់តទៅទៀតដើម្បីស្រោចស្រង់ប្រទេស ដែលលិចលង់ច្រើនឆ្នាំមកហើយណាស់...។

ឱកន្លែងដ៏មនោរម្យ ! ដែលធ្លាប់ផ្តល់នូវវិជ្ជានិងសេចក្តីសុខគ្រប់បែបយ៉ាង ! ខ្ញុំមិនភ្លេចអ្នកទេ ! ទោះបីអាចោរព្រៃសម្លាប់ខ្ញុំ ក៏វិញ្ញាណក្ខន្ធខ្ញុំហើរមកនៅទីនេះវិញដែរ ។ សូមអ្នកអភ័យទោសដល់ខ្ញុំ ដែលមិនបានចូលលាដល់កន្លែង ព្រោះខ្ញុំជាមនុស្សមានទោស មិនអាចមានសេរីភាពធ្វើអ្វើកើតតាមចិត្តចង់ ! តែខ្ញុំមិនតូចចិត្តឡើយ នូវទោសកំហុសដែលបារាំងវាចោទ ដោយសារខ្ញុំស្រឡាញ់ជាតិ-សាសនា ខ្ញុំស្លាប់ក៏ស្លាប់ចុះឲ្យតែជាតិ ! សាសនារស់...។

កប៉ាល់បើកមកដល់មុខវាំង ញាំងចិត្តលោកគ្រូអាចារ្យ ហែម-ចៀវ និងមិត្តភក្តិឯទៀតឲ្យក្តៅឆេះឆួលហួសប្រមាណ, លោកស្អប់ខ្ពើមពួកស្តេចដែលកាចឃោរឃៅ សម្លាប់មនុស្សគ្មានពិចារណា រកយុត្តិធម៌ គ្មានគិតប្រជារាស្ត្រក្រីក្រ ល្ហេមល្ហាម ដែលពួកបរទេសសង្កត់សង្កិន មានចិន យួន បារាំងជាដើម ។ មើលចុះវាំងប្រាសាទរបស់គេមានរស្មីភ្លឺរន្ទាល អស់លុយជាតិរាប់រយលាន ! ចំណែកលំនៅប្រជារាស្ត្រ រកតែស្លឹកបាំងមិនជិតទឹកភ្លៀងនិងកំដៅផង ! គេទុកខ្លួនគេជាអ្នកគ្រប់គ្រងប្រជារាស្ត្រ ។ តែតាមពិតពួកគេជាបក្សនៃប្រជារាស្ត្រទើបត្រឹមត្រូវ ទើបសមនឹងសកម្មភាពដែលគេបានប្រព្រឹត្ត ។ ការឈឺចិត្ត ការភ្ញាក់រលឹករបស់លោកអាចារ្យ ហែមចៀវ មានតាំងពីលោកនៅជាសិស្សសាលាបាលីជាន់ខ្ពស់ម្ល៉េះ ។ លោកជាមេបដិវត្ត

ន៍ដ៏ឧត្តមម្នាក់ដែលយើងកម្រនឹងបានជួប ។

បន្តិចក្រោយមក នាវាចំបាំងដឹកអ្នកទោសនេះ ក៏មកដល់មុខសាលាបាលីជាន់ខ្ពស់ ដែលជាទីបណ្តុះវិជ្ជារបស់លោក ។ លោកសម្លឹងកំពូលសាលាដោយចុកណែនឱរា ហើយបង្កើតសម្លេងតាមខ្យល់ទៅសិស្សកំសត់ ៖

- ឱសិស្សជាទីស្នេហាអើយ ! តើអ្នកបានគ្រូណាបង្រៀនអ្នកទៀត ! បើខ្ញុំត្រូវបរទេសគេដឹកទៅប្រហារជីវិតដូច្នេះ ! ខ្ញុំមិនចង់ឃ្លាតអ្នកទេ ! អ្នកជាសិស្សប្រកបដោយធម៌ ចេះស្រឡាញ់វិជ្ជាដូចចិត្តគ្រូប៉ងប្រាថ្នា ! ថ្ងៃនេះខ្ញុំឃ្លាតពីអ្នកហើយ ! ចូរអ្នកខំសិក្សាជាមួយគ្រូថ្មីឲ្យមែនទែន បើអ្នកពិតជាស្រឡាញ់ខ្មែរមែន ! ចូរអ្នកខំរក្សាកិត្តិយស សាសនា យើងកុំឲ្យសាបសូន្យណា ! ខ្ញុំគ្មានអ្វីផ្ញើមកអ្នកក្រៅពីបណ្តាំមួយម៉ាត់នេះទេ គឺបើអ្នកស្រឡាញ់ខ្ញុំ ទុកខ្ញុំជាគ្រូត្រូវខំរៀន ហើយរំដោះប្រទេសឲ្យបានឯករាជ្យឡើង ។

ជយោសាលាបាលី ! ខ្ញុំលាហើយ លាទាំងមិនបានឃើញមុខអ្នករាល់គ្នា លាហើយកន្លែងធ្លាប់រៀន ធ្លាប់ជុំគ្នា ! លាហើយមាតុភូមិជាទីស្នេហាស្មើដោយជីវិត ! លាហើយញាតិមិត្ត ដែលធ្លាប់ស្រឡាញ់រាប់អានគ្នាឥតមានហ្មង... លាហើយទីក្រុងកំសត់ដែលត្រូវគេសង្កត់សង្កិន ! លាហើយប្រិយមិត្រដែលគិតប្រយោជន៍ជាតិ ! ខ្ញុំលាទាំងអាល័យនិងឈឺចិត្តជាទីបំផុត !

ចំណែកលោក នួន-ឌួង និងលោក ប៉ាច-ឈឺន ក៏មានជុំទុក្ខដូចជាលោកគ្រូហែម-ចៀវ ដែរ ។ លោកប៉ាច-ឈឺនក្តី លោក នួន-ឌួងក្តី លោកគ្រូអាចារ្យហែមចៀវក្តី និងអ្នកឯទៀតក្តី គ្មានស្តាយស្រណោះជីវិតទេ តែសាកស្តាយខានបានបន្តសកម្មភាព ដើម្បីរំដោះជាតិឲ្យរួចពីនឹមដែកអាណានិគមនិយមបារាំងឲ្យរួចសិន ។ ការគិតវែងឆ្ងាយនូវបញ្ហាជាតិទាំងនេះហើយ ដែលធ្វើឲ្យជលនេត្រវីរបុរសខ្មែរយើងហូរដោយមិនដឹងខ្លួន ។ លោកទាំងនេះពុំបានសន្ទនាគ្នានៅតាមសម្លេងទេ គឺគ្រាន់តែសន្ទនាតាមខ្សែភ្នែកប៉ុណ្ណោះ ។

ដំណើរនាវាទៅមុខជានិច្ច ឥតគិតដល់មនុស្សដែលមានទុក្ខទោសហួសព្រំដែនសោះឡើយ ។ ទេសភាពដងទន្លេពីភ្នំពេញទៅព្រែនគរមានសភាពក្រៀមក្រំសម្ងំស្ងៀមឈឹង ហាក់ដូចជាឈរគោរពវីរបុរសដែលបារាំងដឹកទៅកាត់ទោសនាក្រុងព្រៃនគរក្នុងពេលខាងមុខនេះ ។ សភាពស្ងប់ស្ងាត់នេះ រឹងរឹតតែទាញព្រលឹងវីរជនយើងឲ្យរំភើបឥតឧបមា ។

នៅពេលដែលនាវាបើកហួសព្រំប្រទល់ដែនខ្មែរ លោកនួន-ឈួង បានបន្លឺសម្លេងទៅកាន់លោកអាចារ្យហែម-ចៀវដោយញ័រៗ ៖

- ព្រះតេជព្រះគុណ យើងឃ្លាតពីមាតុភូមិយើងហើយ !

- អើលោក ! នេះជាការធម្មតារបស់យើងទេ... សូមកុំទោមនស្សអី !

- ពិតមែនហើយ ! តែព្រលឹងខ្ញុំវាមិនព្រមដាច់អាល័យពីខ្មែរយើងសោះ !

- អើ ! ខ្លួនខ្ញុំក៏យ៉ាងនោះដែរ ! ខ្ញុំមិនអាចបំភ្លេចជាតិយើងបានទេ ទោះបីបារាំងសម្លាប់ចោលក៏ដោយ ខ្ញុំមិនគិតដែរ គឺខ្លាចតែប្រទេសយើងពុំបានសេរីភាពប៉ុណ្ណោះ ។

លោក នួន-ឌួង ឆ្លើយ ៖

- មិនអីទេ ខ្មែរយើងភ្ញាក់រលឹកខ្លះហើយព្រះតេជព្រះគុណ !

កំពុងសន្ទនាគ្នាជាប់មាត់ ស្រាប់តែសក្តិ២បារាំងដើរមកជិតហើយស្រែក ៖

- ឈប់ជជែកគ្នាទៅ ! រៀបចំខ្លួនឡើងដល់ផែឥឡូវហើយ !

អ្នកទោសទាំងអស់ក៏ធ្វើតាមបារាំងនោះ ។

ដល់ព្រៃនគរ រថយន្តទ្រុងមួយបានមកដឹកអ្នកទោស យកទៅដាក់ក្នុងគុកធំ ។ អំពើយង់ឃ្នងនៅគុកព្រៃនគរ ក៏ដូចជានៅគុកធំភ្នំពេញដែរ ។

ពួកអ្នកចូលថ្មី តែងទទួលថ្នាំខ្លាំងពីអ្នកទោសដៃឆើតស្ទើរគ្រប់គ្នា ។ អំពើប្រាសចាកមនុស្សធម៌នេះកើតដោយសារពួកបារាំងវាបង្កើតឡើង កុំឲ្យអ្នកទោសត្រូវនឹងអ្នកទោស គឺជានយោបាយបំបែកបំបាក់ ដើម្បីស្រួលត្រួតត្រាទៅទៀត ។ ខ្មែរអ្នកទោសខ្លះដោយបារាំងកាន់ជើង ខ្លួនក៏ឡើងដៃ វាយធ្វើបាបជាតិឯងគ្មានគិតមុខគិតក្រោយអ្វីសោះ ។ ពេលចូលទៅដល់ លោក នួន-ឌួង បានត្រូវមេតម្រួតគុកព្រៃនគរវាយធាក់រហូតសន្លប់បាត់ស្មារតី លែងដឹងខ្លួននៅចំពោះអ្នកទោសជាច្រើន ព្រោះតែលោកឆ្លើយថា «ក្បត់បារាំង» អំពើនេះធ្វើឲ្យកល្យាណមិត្តលោកអាណិតស្ទើរភ្លេចស្មារតី ។ អាចារ្យ ហែម-ចៀវ ឃើញមិត្តខ្លួនទទួលទណ្ឌកម្មដ៏សាហាវដូច្នេះ លោកបារម្ភក្នុងចិត្តខ្លះដែរ ដោយខ្លាចទទួលរង្វាន់អប្រិយពីជនទុយ៌ស ដូចលោក នួន-ឌួង ។ តែខណៈនោះលោកនឹកឃើញ «នេះជាការធម្មតារបស់អ្នកទោសទេ ! នេះហើយជាស្ថាននរកលោកិយ ! អញមិនត្រូវរុញរាឡើយ...» បន្ទាប់ពីពួកឃ្មួនវាធ្វើបាប លោកអារ្យ នួន-ឌួង អស់ចិត្តហើយ ជនអប្រិយនោះក៏មកហៅអាចារ្យ ហែម-ចៀវ ទៅសួរម្តង ។ លោកអាចារ្យក៏ចូលទៅជិតតាមទម្លាប់គេនិយមអនុវត្តនោះ ដោយមិនហ៊ានងើបមើលមុខគេផង ។ មេត្រួតត្រាក៏បោះសំដីទាំងកំរោលទៅកាន់អាចារ្យហែម-ចៀវ ៖

- ចុះអាទ្រើកនោះមានរឿងអីដែរ ?

លោកអាចារ្យក៏ឆ្លើយទៅវិញ ៖

- ប្របាទព្រះតេជព្រះគុណម្ចាស់ ! ខ្ញុំបាទត្រូវបារាំងចាប់ជាមួយគ្នា ដោយសង្ស័យថាខ្ញុំក្បត់បារាំង, តែតាមពិតបារាំងគេនិមន្តខ្ញុំ ឲ្យដើរទេសនាពន្យល់អ្នកស្រុក

ទាហានកុំឲ្យទាស់គ្នា ។ លុះឃើញពួកទាំងនោះចូលចិត្តខ្ញុំបាទច្រើន បារាំងភ័យខ្លាចខ្ញុំបំបះបំបោរ គេក៏ចាប់ខ្ញុំបាទមក !

– អើមិនអីទេអាឯងរួចខ្លួន ! ទៅកន្លែងវិញចុះ !

ចាប់តាំងពីចូលមកនៅក្នុងគុកព្រៃនគរ លោកអាចារ្យ ហែម-ចៀវ មិនដែលប្រើអាកាប្បកិរិយាច្រឡើសបើសទេ, លោកតែងនិយាយណែនាំអប់រំអ្នកទោសខ្មែរស្រឡាញ់អ្នកទោសខ្មែរ កុំឲ្យភ្លេចជាតិខ្លួន ។ មិនត្រឹមតែខ្មែរយើងទេដែលស្រឡាញ់លោកអាចារ្យ សូម្បីតែពួកជាប់ពន្ធធនាគារជាមួយក៏ស្រឡាញ់គោរពដល់លោកជារឿយៗដែរ ។ កិរិយាសុភាពរាបសា សំដីពិរោះ ចិត្តល្អមិនចេះឈ្លានិះជនណាមួយដូចលោកអាចារ្យ ហែម-ចៀវ តែងបានទទួលនូវសេចក្ដីអាណិតអាសូរពីអ្នកផងជានិច្ច ។ គេបានដាក់លោកទាំងពីរនៅលើអាគារជាន់ទី៤ បន្ទប់លេខ៣ ។ គុកនៅព្រៃនគរមានសភាពស្អាតស្អំធំទូលាយជាងគុកនៅភ្នំពេញច្រើន ហើយសំលៀកបំពាក់សោតក៏លើភ្នំពេញដែរ ។ តើបញ្ហានេះមកពីអ្វី បើយើងទាំងពីរកញ្ចះបារាំងដូចគ្នា ?

ការជំនុំអ្នកទោសខ្មែរយើងពីរបីដងទៅហើយ នៅតែមិនទាន់សំរេចថាយ៉ាងណាសោះ ។ ឃើញតែព្រះអាចារ្យ ប៉ាង-ខាត់ មួយត្រូវរួចវិលមកភ្នំពេញវិញ ។

«ចំណែកអស់លោកឯទៀតកំពុងនិទ្រាគងថ្ងាស ជញ្ជឹងគិតថា តើវាសនាអញនឹងធ្លាក់ដល់ណា ! តែស្អីក៏ស្អីទៅចុះ ព្រោះជីវិតអញៗបានបូជាជូនជាតិស្រេចទៅហើយ» ការប្ដេជ្ញាចិត្តបែបនេះហើយ ដែលធ្វើឲ្យវីរបុរសទាំងនោះគ្មានតក់ស្លុតអ្វីសោះ ។ រហូតមកដល់មានអស់លោកខ្លះ ស្រែកជេរឲ្យស័ក្ដិប្រាំបារាំងថា ៖

– «ពួកអាវ៉ែងចង់ធ្វើអីអញក៏ធ្វើទៅចុះ ! អាចោរលួចប្រទេសអញ ! អញខ្ពើមរស់ ក្រោមការជិះជាន់របស់អាឯងណាស់អាហាន្ទយុំ ! អាកំសាក ! សម្លាប់អញទៅ»

ថ្ងៃកាត់ទោសក៏មកដល់ !

ក្រោយពីជំនុំជំរះសម្រេចសេចក្ដីមក លោកស័ក្តិប្រាំចាងហ្វាងតុលាការសឹកបានកាន់សំណុំរឿង ចេញមកឈរនៅចំពោះមុខអ្នកទោសខ្មែរយ៉ាងក្លាហាន ដោយមានខ្មែរយើងម្នាក់ជាអ្នកបកប្រែភាសាអមផង ។ ជាបឋមគេហៅឈ្មោះលោកប៉ាចឈឺន ។ លោកប៉ាច-ឈឺន ក្រោកឈរយ៉ាងសង្ហាររួចឆ្លើយ ៖

– បាទ !

– អ្នកឯងត្រូវមានទោសប្រហារជីវិតបង់ ! ឯលោកហែម-ចៀវ ក៏មានទោសប្រហារជីវិតដែរ ! លោក នួន-ឌួង ក៏មានទោសប្រហារជីវិតដែរ ! ចំណែកលោកប៉ុណ្ណ-ចន្ទមុ៉ល មានទោសគុក៥ឆ្នាំ និងនិរទេសមិនឲ្យចូលស្រុក១៥ឆ្នាំទៀត ។ល។

ក្នុងចំណោមអ្នកទោសតាំងនេះមានតែលោកប៉ុណ្ណ-ចន្ទមុ៉លម្នាក់ទេដែលភ័យ

ខ្លះ ព្រោះលោកមានវ័យក្មេងជាងគេ ។ ចំណែកលោកប៉ាច-ឈឺន, អាចារ្យហែម-ចៀវ, អាចារ្យនួន-ឌួង នៅមានស្មារតីរឹងប៉ឹងដដែល ។ លោកទាំងបីប្រាណញញឹម ដោយការឈឺចាប់ឥតឧបមា ចំពោះការកាត់ទោសដ៏លាមកនេះ ។ បន្ទាប់មកលោកស័ក្តិប្រាំនោះ ក៏ពោលមកកាន់អ្នកទោសប្រហារជីវិតបង់ ៖

- យើងនឹងបញ្ជូនសំណុំរឿងអ្នកឯង ទៅសុំសំរាលទោសពីលោកឧត្តមសេនិយ ប៉េតាំង ប្រមុខរដ្ឋាភិបាលបារាំង ដើម្បីឲ្យលោកអនុគ្រោះទោសខ្លះដល់អ្នករាល់គ្នា ។

សម្លេងរបស់លោកស័ក្តិប្រាំចប់ដោយស្ងៀមស្ងាត់ គ្មានពុអ្នកទោសខ្មែរណាម្នាក់ ថ្លែងនូវអំណរគុណសោះឡើយ ។ លោកស័ក្តិប្រាំកំណាចនោះក៏បញ្ជាឲ្យភ្នាក់ងារគុក នាំអ្នកទោសវិលមកាន់ទីឃុំឃាំង ។

រវាង២ខែក្រោយ លោកអាចារ្យហែម-ចៀវ មានចិត្តអាណិតអាសូរលោកប៉ុ-ណ្ណា-ចន្ទម៉ុលនិងមិត្តឯទៀតណាស់ ដោយត្រូវគេបញ្ជូនទៅឲ្យនៅគុកឯកោះត្រឡាច ។ ឯលោកទាំងបីមិនទាន់បញ្ជូនទៅភ្លាមៗទេ ព្រោះរង់ចាំសេចក្តីសំរេចចិត្តពីឧត្តមសេនិយ ប៉េតាំង សិន ។

❑ ❑

❑

ផ្កាបណាខ្មែរលែងមានគំនិតក្តិចខ្មែរ
ផ្កាបនោះជាតិយើងនឹងបានរុងរឿងមិនខាន ។

## កថាទីប្រាំពីរ

# ព្រះអាចារ្យហែម-ចៀវ មរណៈក្នុងគុកកោះត្រឡាច

ការរស់នៅក្នុងពន្ធនាគារមួយឆ្នាំ ប្រៀបដូចយើងរស់នៅខាងក្រៅមួយសតវត្ស ។ លោកអាចារ្យហែម-ចៀវ ចាប់តាំងពីបារាំងផ្សឹកមក លោកមិនដែលទទួលទានអាហារល្ងាចទេ ។ វីរជននេះមិនត្រឹមតែមិនពិសារអាហារល្ងាចប៉ុណ្ណោះទេ គឺលោករក្សាសិលប្រាំបីជាប់ជានិច្ចផង ។

ទឹកភ្នែករបស់លោកអាចារ្យ តែធ្លាក់ស្ទើររាល់ទិវារាត្រី ដោយឃើញមនុស្សទោសទាំងនុ៎ះ ត្រូវគេធ្វើបាបជាងសត្វតិរច្ឆានទៅទៀត ។ ពេលនោះហើយដែលព្រះអាចារ្យ យកគុកជាសាលារៀន ស្ដីពីសង្គមសាស្ត្រ ។ មហាបុរសនេះនឹកគិតថា «ក្នុងលោកសន្និវាសយើងនេះ គ្មានសត្វណាអាក្រក់ជាងមនុស្សយើងទេ ! មួយថ្ងៃៗ ឃើញតែកាប់ចាក់ ទាត់-ធាក់-ដាក់ខ្នោះវាយដំ ប្រហារជីវិតគ្នាដោយឥតត្រាប្រណីអ្វីឡើយ ។ មើលចុះ ! អ្នកធំធ្វើបាបអ្នកតូច ! ស្ដេចហុតឈាមរាស្ត្រ សម្លាប់រាស្ត្រតាមទំនើងចិត្តរបស់គេ ។

ប្រទេសតូចតាចត្រូវមហាអំណាចប្លន់ត្រួតត្រា ! អ្នកស្រែចម្ការធ្វើការពីព្រលឹមទល់ព្រលប់ គ្មានបានរបស់អ្វីឆ្ងាញ់ក្រៅពីបាយនិងប្រហុកមួយខ្ទប់ឡើយ។ ឯស្ដេចមន្ត្រីធំៗ នាយទុន ដេកស្រណុកស៊ីសុទ្ធតែម្ហូបឆ្ងាញ់ៗ ! មានតែស្ថានសួគ៌របស់មនុស្ស ? គ្មានទេព្រះអើយ ! មានតែស្ថាននរកអព្វមង្គលតែមួយប៉ុណ្ណោះ ! ការពិតសង្គមមនុស្សចំរើនតែអំពើអយុត្តិធម៌ អមនុស្សធម៌ ហុតឈាមគ្នាឥតឈប់ឈរសោះតាំងពីផែនដីនេះកើតឡើង !

ឱបងប្អូនរួមជាតិអើយ ! ចូរភ្ញាក់ស្មារតីឡើង ទើបយើងកំចាត់ពួកបារាំង ឬពួកអភិជនឲ្យវិនាសសាបសូន្យបាន !

រាស្ត្រនេះហើយដែលដឹងទុក្ខធុរៈរាស្ត្រពិតប្រាកដ កុំចេះតែជឿសំដីបោកប្រាស់របស់គេនុ៎ះ មិនសមជាពុទ្ធបរិស័ទឡើយ ព្រះអង្គយកខ្លួនយើងជារំពឹង យកអ្នកដទៃជាពឹង មិនមែនជាវិធីទៅកាន់សេចក្ដីសុខទេ... យើងនឹងនាំខ្លួនយើងឲ្យធ្លាក់ចុះក្នុងទាសភាពគេមិនខាន ។

ក្នុងវាលវដ្តសង្សារដ៏ធំធេងនេះ គ្មានអ្វីប្រសើរជាងការធ្វើខ្លួនយើងម្នាក់ៗ ឲ្យមានសេរីភាពសម្បូរសប្បាយនោះឡើយ ចំណែកខ្លួនខ្ញុំ ៗរើបម្រះមិនរួចទេតាមផ្លូវកាយតែតាមផ្លូវចិត្តវិញខ្ញុំឈ្នះជនកំណាចឈ្លានពានទាំងនេះហើយសូមបងប្អូនបន្តកិច្ចការនេះកុំបីរុញរាឲ្យសោះ ទើបយើងបានសុខ បើយើងខ្លាចឬមិនស្រុះស្រួលគ្នាការប្រយុទ្ធរបស់យើងមុខជាមិនឈ្នះយ៉ាងដាច់ខាត ។ ជីវិតយើងរស់គ្មានសេរី តើយើងរស់ថោកទាបដូចសត្វតិរច្ឆាន ? ខំទៅឿយមុនស្រណុកក្រោយ !» ។ លោកគិតមិនចេះចប់មិនចេះហើយ ចំពោះសេចក្តីទុក្ខរបស់ប្រជារាស្ត្រស្លូតត្រង់ ។

រំលងជាច្រើនខែមក ទើបឃើញលិខិតរបស់លោកប៉េតាំង ប្រមុខរដ្ឋាភិបាលបារាំងផ្ញើមកចាងហ្វាងតុលាការ អនុញ្ញាតឲ្យលោកទាំងបីនាក់ នៅត្រឹមជាប់គុកអស់មួយជីវិត ហើយធ្វើការជាទម្ងន់ផង ។ ថ្វីបើការសំរេចទោសយ៉ាងនេះក៏ដោយ លោកទាំងបីពុំសប្បាយចិត្តនឹងអំពើនេះទេ ។ លោកមិនចង់រស់ទទួលគ្រោះថ្នាក់បែបនេះតទៅទៀតឡើយ... លោកចង់សម្លាប់ខ្លួនឲ្យហើយតែម្តងទៅ ! តែលោកចង់ឃើញវាសនាប្រទេសនឹងទៅបែបណា !

ខែមិថុនា១៩៤៣ លោកប៉ាច-ឈឺន, លោកនួន-ឌួង និងព្រះអាចារ្យហែម-ចៀវ ត្រូវបារាំងបញ្ជូនពីគុកធំព្រៃនគរទៅគុកធំឯកោះត្រឡាច ។ គេដាក់លោកទាំង៣នៅគុកលេខ៩ ដែលជាកន្លែងទោសឧក្រិដ្ឋអស់មួយជីវិត ។ ទីនេះហាមមិនឲ្យអ្នកក្រៅចូលសួរសុខទុក្ខទេ ។ អ្នកទោសត្រូវធ្វើការគ្រប់បែបយ៉ាង ដែលបារាំងវាតម្រូវឲ្យធ្វើ ។

កោះត្រឡាច មានវិសាលភាពដ៏ធំធេង ស្ថិតក្នុងកណ្តាលសមុទ្រ ។ មានផ្ទះរាប់ពាន់ខ្នង សង់តាមមាត់សមុទ្រ... ព្រៃប្រឹក្សាគ្រប់លើភ្នំ គួរឲ្យសង្វេគ ។ ដីមានជីរជាតិល្អណាស់ ។ គេឲ្យអ្នកទោសដាំដំណាំគ្រប់មុខ ។ ជនដែលមានចិត្តស្រាលតែងយំនឹកស្រុកកំណើតស្ទើររាល់ថ្ងៃ ។ អ្នកទោសត្រូវបង្ខំឲ្យធ្វើការជាងសត្វពាហនៈ មានជនខ្លះ រស់នៅលើកោះត្រឡាចបានតែពីរបីថ្ងៃក៏ឈឺស្លាប់ទៅ ។

នៅរដូវរងារម្តងៗ អ្នកទោសមានសេចក្តីទុក្ខវេទនាសំបើមណាស់ ដោយខ្លួនគ្មានអ្វីការពារឲ្យបាត់ត្រជាក់បានទេ ។

ព្រះអាចារ្យ ហែម-ចៀវ និងលោក នួន-ឌួង ដែលមិនសូវមានសុខភាពស្រាប់ផង ក៏មានជម្ងឺជាញឹកញយ ។ លោករស់នៅក្នុងតំបន់ ដិក-យុក បានរវាង៦ខែ ស្រាប់តែមានជម្ងឺមួលមករុករានកាយជាទម្ងន់ ។ ជម្ងឺកាន់តែដាបណាស់ទៅហើយ លោកអាចារ្យ ហែម-ចៀវ ក៏បន្លឺវាចាទៅកាន់អាចារ្យ នួន-ឌួង ជាកូនសិស្ស ៖

- អាចារ្យ ឌួង ?

- មានការអីព្រះតេជព្រះគុណ !...

- អាការរោគខ្ញុំ ប្រហែលមិនជាទេអាចារ្យអើយ ខ្ញុំស្ដាយណាស់ ស្ដាយដោយមិនបានវិលទៅជួបមុខប្រជារាស្ត្រយើងវិញ ! ខ្ញុំមុខជាចោលឆ្អឹងនៅកោះត្រឡាចនេះជាមិនខាន សូមអាចារ្យឯងតាំងស្មារតីឲ្យមែនទែន បើខ្ញុំស្លាប់ទៅ ! កុំតក់ស្លុតឲ្យសោះ ធ្វើម៉េចសង្ខារមនុស្ស រមែងស្លាប់ទៅជាធម្មតា ។

- ព្រះតេជព្រះគុណ ! សូមកុំទាន់អស់សង្ឃឹមពេក មុខតែនឹងជាវិញទេ... គ្រូពេទ្យគេកំពុងព្យាបាលយើងរាល់ថ្ងៃ !

- គេព្យាបាលយើងមែន តែគេធ្វើសោះនឹងខាន យើងឃើញស្រាប់ហើយមានថ្នាំអីឲ្យយើងផឹក ! រោគមួលនៅទីនេះមិនមែនស្រួលមើលដូចនៅស្រុកយើងទេ គឺ៩០%ត្រូវស្លាប់... ខ្ញុំរាល់ថ្ងៃដេកចាំតែស្លាប់ប៉ុណ្ណោះ ។ តែទោះបីយ៉ាងណាក៏ដោយ សុំធ្វើចិត្តព្រងើយកុំកើតទុក្ខអីចំពោះរូបខ្ញុំមួយ...។

- យើងពីរនាក់គឺជីវិតតែមួយ... បើព្រះតេជព្រះគុណស្លាប់ ខ្ញុំក៏ស្លាប់ដែរ ! ។

- វាពិតហើយអាចារ្យ ខ្ទួង យើងបានបំរើជាតិរួមគ្នា ជាប់គុកក៏រួមគ្នាទៀត ។

ព្រះអាចារ្យ ហែម-ចៀវ ពោលមកដល់ត្រឹមណោះក៏អួល ដើររកបារមាត់និយាយតទៅទៀតពុំកើត ក៏ទាញកន្សែងជូតទឹកភ្នែក ដែលកំពុងរមៀលចេញពីរន្ធភ្នែកដ៏ខូង កាត់តាមថ្ពាល់ជ្រីវជ្រួញនៃវរដ្ឋបុរសអភ័ព្វ ។ រីឯលោក នួន-ខ្ទួង ថ្វីបើខ្លួនលោកមានជម្ងឺដែរក៏ដោយ លោកនៅថែទាំបំរើគ្រូរបស់ខ្លួន ឥតហ៊ានដើរចោលទៅណាឡើយ ។

- ព្រះតេជព្រះគុណ កុំគិតច្រើនពេក !

សំដីលោក នួន-ខ្ទួង ចេញទាំងរអាក់រអួលដូចកូនក្មេងត្រូវគេវាយដំ ។ លោកមានឱវាទវាចាបន្តទៅទៀត ៖

- បើសង្ខារយើងមិនអស់ មិនស្លាប់ទេ ! យើងនឹងរស់នៅ ហើយបានវិលទៅស្រុកថែមទៀត ។

- អើខ្ញុំស្ដាប់បានហើយ ! តែពីយប់មិញនេះសុបិន្តនិមិត្តប្រាប់ខ្ញុំថា «សង្ខារចៀវឯងត្រូវអស់ពេលនេះហើយ !» អាចារ្យខ្ទួង !

- មិនមែនទេព្រះគុណ ! គឺពិតជាការស្រមើស្រមៃរបស់ព្រះគុណ... សុំឲ្យព្រះតេជព្រះគុណសម្ងំសំរាកកុំឲ្យនិយាយច្រើនពេក នាំតែអស់កម្លាំងឥតប្រយោជន៍ទេ...។

- អាចារ្យ ខ្ទួង តើលោកប៉ាច-ឈឺន បានដឹងថាខ្ញុំឈឺឬទេ ?

- លោកចីមិនដឹង ! ពីម្សិលមិញលោកបានមកសួរសុខទុក្ខដែរ ប៉ុន្តែព្រះតេជ

ព្រះគុណាសន្តប់មិនដឹងខ្លួន ! ។

- ចុះប្អូន ប៊ុណ្ណចន្ទ-ម៉ុល ?

- ប្អូនម៉ុលមិនទាន់មកទេ គ្រាន់តែផ្ញើថ្នាំមកនឹងគេឲ្យយើងថាមកមិនទាន់រួច ។

- ខ្ញុំចង់ឃើញមិត្តយើងទាំងអស់ណាស់ មុននឹងលាលោកនេះទៅ...

សម្លេងនេះរីងរីតតែធ្វើឲ្យបេះដូងអាចារ្យ ឌួន-ឌួង ញាប់ញ័រ ភ័យព្រួយ ចំ-ពោះលោកគ្រូជាទីគោរព តែមួយក្នុងលោកដែលកម្រនឹងរកបាន ។ ជលនេត្រលោកហូរឥតដឹងខ្លួន ។ លោកគ្រូ ហែម-ចៀវ ទាញដៃលោក ឌួន-ឌួង មកដាក់លើដើមទ្រូងដូចជានឹកខ្លាំងណាស់ ។

នៅឯលើមេឃ ផ្គរលាន់គ្រហឹមកាន់តែរន្ថើនឡើងៗ ហាក់ដូចជាចង់ទាញព្រលឹងអាចារ្យ ហែម-ចៀវ ឲ្យផុតពីដីកោះត្រឡាចមួយរំពេច ។ មេឃងងឹតស្លុប ខ្យល់គួចដុំពពកខ្មៅរដេរដាស ។

បន្តិចក្រោយមក ព្រះវរុណក៏បង្អុរដូចគេចាក់ទឹកពីក្អម ដែលធ្វើឲ្យអ្នកជម្ងឺរងារស្ទើរទ្រាំមិនបាន ។

រំពេចនោះលោកប៊ុណ្ណចន្ទ-ម៉ុលក៏ចូលមកដល់ ឃើញលោកអាចារ្យទាំងពីរញ័រដូចកូនសត្វដូច្នេះ លោកមានចិត្តរំភើបឥតឧបមា ស្ទើរតែរកពាក្យនិយាយមិនរួច ។ ទាំងបីនាក់មានមុខជោកដោយទឹកភ្នែកទាំងមិនដឹងខ្លួន ។

- លោកគ្រូ ! បានស្រួលខ្លួនខ្លះឬទេ ?

- មិនអីទេប្អូនម៉ុល ។

លោកអាចារ្យ ហែម-ចៀវ ប្រឹងញញឹមទាំងទឹកភ្នែក បែរមុខទៅកាន់លោកប៊ុណ្ណចន្ទ-ម៉ុល រួចបន្លឺវាចាថា ៖

- កុំព្រួយអីប្អូន ! រូបខ្ញុំស្លាប់ចុះមិនស្តាយទេ ខ្ញុំស្តាយតែខានបានទៅឃើញវាសនាប្រទេសយើងប៉ុណ្ណោះ ។ សូមកុំភ្លេចការបដិវត្តន៍របស់យើងណា៎ ! យើងត្រូវតែធ្វើឲ្យបានសំរេចកុំបោះបង់ចោល !

- បាទលោកគ្រូ ! ដរាបណាខ្ញុំនៅរស់នឹងធ្វើតាមបណ្តាំលោកគ្រូរហូតបានសំរេចទើបឈប់ ។

- លោកម៉ុលឯងចេះតែបានសុខសប្បាយទេឬសព្វថ្ងៃ ?

- បានសុខសប្បាយទេ !

- លោកម៉ុលឯងល្មមវិលទៅវិញចុះ ក្រែងគេធ្វើទោស យើងទាំងពីរត្រេកអរណាស់ ដែលលបមកសួរជម្ងឺខ្ញុំដូច្នេះ !

- បាទមិនអីទេ ! ខ្ញុំចង់មកថែទាំណាស់ តែធ្វើទៅពុំកើត !

- កុំគិតវែងឆ្ងាយពេក នៅទីនេះមិនមែនផ្ទះយើងទេ យើងបានជួបមុខគ្នាប៉ុណ្ណោះ គឺជាសំណាងធំហើយមែនទេឌួង ?

- ត្រូវហើយ ! ទីនេះជាស្ថាននរក មិនមែនជាមន្ទីរពេទ្យទេ ។

ការសន្ទនាគ្នាផ្សេងៗបានព្រព្រឹត្តទៅអស់រយៈជិតមួយម៉ោង ទើបលោកប៊ុណ្ណចន្ទ-ម៉ុលវិលត្រឡប់ទៅកន្លែងវិញ ។

មួយថ្ងៃកន្លងមក ស្តេចមច្ចុរាជក៏មកផ្តាច់សង្ខារលោកគ្រូអាចារ្យ ហែម-ចៀវ ចោលលោក ឌួន-ឌួង ឲ្យនៅតែឯងត្រមង់ត្រមោចកណ្តាលកោះត្រឡាច ។ មហាបុរសវដ្ឋនេះបានទទួលមរណៈក្នុងជន្មាយុ៤៥ឆ្នាំ ក៏ព្រោះតែស្រឡាញ់ជាតិមាតុភូមិ មិនព្រមរស់នៅក្រោមអាណានិគមនិយមបារាំងសែស ។

ពីរថ្ងៃក្រោយមក លោកប៊ុណ្ណចន្ទ-ម៉ុល បានមកសួរទៀត ស្រាប់តែបាត់លោកគ្រូអាចារ្យ ហែម-ចៀវ ឃើញតែលោក ឌួន-ឌួង កំពុងសំរាន្តដោយអស់សង្ឃឹម

- ប្អូនម៉ុល ! លោកគ្រូអាចារ្យយើងស្លាប់ទៅហើយ !

- លោកស្លាប់ពីថ្ងៃណា ? មានផ្តាំអ្វីខ្លះទេ ?

- លោកស្លាប់ពីរថ្ងៃហើយ ! ស្លាប់នៅលើភ្លៅរបស់ខ្ញុំ ! មុននឹងស្លាប់លោកបាននិយាយថា «សូមអាចារ្យឯងប្រាប់មិត្តទាំងឡាយថា ខ្ញុំមិនរស់ទេ» ការកសាងទឹកដីធ្វើតែម្នាក់ឯង ពុំបានសំរេចជោគជ័យជាដាច់ខាត, ត្រូវរួមគ្នាគ្រប់ជាន់ថ្នាក់ឲ្យបានច្រើន ហើយចេះតែធ្វើតទៅទៀត ! ចូរអស់លោកខំកសាងជំនួសរូបខ្ញុំតទៅទៀតចុះ ។ ខ្ញុំពារដែនដីម្នាក់ឯងមិនរួចទេ... ផែនដីយើងទាំងអស់គ្នា... ខ្ញុំមិនខ្លាចសេចក្តីស្លាប់ទេ តែខ្ញុំនៅនឹកស្តាយត្រង់មិនបានឃើញប្រទេសកម្ពុជាបានឯករាជ្យម៉្យាងប៉ុណ្ណោះ ។ សូមលោកនៅឲ្យបានសុខកុំបីខាន... បើចង់ឲ្យប្រទេសយើងបានសុខត្រូវរៀចំជាសាធារណរដ្ឋ កុំភ្លេចណា៎ ! ខ្ញុំលាហើយលោក...» ។

បណ្តាំដ៏មានខ្លឹមសារនេះ ធ្វើឲ្យលោកប៊ុណ្ណចន្ទ-ម៉ុលកត់ត្រាទុកក្នុងបេះដូងរហូតដល់សព្វថ្ងៃ ។ លោកបានទៅរៀបចំផ្នូរឲ្យវីរបុរសយើងយ៉ាងសមរម្យទៀតផង ។

មិត្តអ្នកអានជាទីមេត្រី ! ព្រះអាចារ្យ ហែម-ចៀវបានស្លាប់នៅកោះត្រឡាចក៏ពិតមែនហើយ តែព្រលឹងរបស់លោកហោះហើរមកសណ្ឋិតក្នុងខួរក្បាលកូនខ្មែរអ្នកស្នេហាជាតិគ្រប់ៗកាល ។ ដោយសារវីរភាពរបស់លោកនេះហើយ ដែលញ៉ាំងខ្មែរយើងឲ្យនាំគ្នាធ្វើនយោបាយ ដេញបារាំងខ្មាតចេញពីមាតុភូមិយើង រហូតដល់បានរបបសាធារណរដ្ឋ ។

យើងទាំងអស់គ្នា សូមគោរពវិញ្ញាណក្ខន្ធរបស់លោកគ្រូអាចារ្យ ហែម-ចៀវ

រដ្ឋបុរសខ្មែរ និងកល្យាណមិត្តលោកលុះដល់ថ្ងៃស្លាប់ ។

អ្នករៀបរៀង

**គង់-សម្ភារ**

❑ ❑

❑

# ពិធីទទួលអដ្ឋិធាតុអាចារ្យ ហែម-ចៀវ

នៅថ្ងៃទី៩ កក្កដា ១៩៧២ គឺជាថ្ងៃប្រវត្តិសាស្ត្រថ្មីមួយ ដែលរដ្ឋាភិបាលបាននាំព្រះអដ្ឋិធាតុព្រះអាចារ្យ ហែម-ចៀវ ពីកោះត្រឡាចមកធ្វើបុណ្យនៅប្រទេសយើងវិញ ក្រោមអធិបតីភាពនៃសម្ដេចសង្ឃទាំងពីរគណៈ និងលោកប្រធានាធិបតីលន់-នល់ ព្រមទាំងជនរួមឈាមជាច្រើនផង ។

ធាតុវីរបុរសនេះ បានតម្កល់ទុកនៅវត្តឧណ្ណាលោមសព្វថ្ងៃ ។

## បន្ថែមពិសេស

# ព្រះអាចារ្យ ហែម-ចៀវ
# «កើត» សាជាថ្មី

★★★ អ្នកតស៊ូខ្មែរមួយរូប ក្នុងចំណោមអ្នកតស៊ូជាច្រើនទៀត ដែលបានបូជាជីវិត ក្នុងការប្រយុទ្ធប្ដូរផ្ដាច់ប្រឆាំងនឹងការជិះជាន់សង្កត់សង្កិន របស់អាណានិគមនិយមបារាំង ហើយដែលត្រូវប្រវត្តិសាស្ត្រជាតិ បានបំភ្លេចចោលក្នុងសម័យរាជានិយម បានទទួលកិត្តិយសរបស់ឡើងវិញ ។ គឺឆ្អឹងរបស់លោកអាចារ្យ ហែម-ចៀវ ដែលគេបានបំបរបង់ទុកចោលនៅបរទេសស្រុកយួន បណ្ដាលឲ្យពេលវេលាស៊ីបំផ្លាញបំបាត់ភស្ដុតាងយ៉ាងងាយបំផុតនូវវីរភាពមួយ ទើបតែនឹងត្រូវដឹកនាំតាមយន្ត-ហោះ វិលត្រឡប់មកកាន់ទឹកដីដែលបានផ្ដល់កំណើតដល់លោក ហើយលោកបានបង្ហូរឈាមដើម្បីតបស្នងគុណវិញ ។

កាលពីព្រឹកថ្ងៃអង្គារម្សិលមិញ (ថ្ងៃទី៤កក្កដា១៩៧២) ពិធីបុណ្យតាមប្រពៃណីសាសនា បានចាត់ចែងឡើងយ៉ាងឧឡារិក ដើម្បីផ្ដល់កិត្តិយសដល់ការតស៊ូ ដែលលោកអាចារ្យ ហែម-ចៀវ បានបូជាជីវិតជូនជាតិ ។ ពិធីបុណ្យនេះបានធ្វើឲ្យចិត្តខ្មែររំភើប បានអង្រួនមនសិការឲ្យនឹកទៅដល់សំរែកឈឺចាប់ ដែលខ្មែរបានទទួលដល់ទឹកភ្នែកនិងដំណក់ឈាម ដែលអ្នកស្នេហាជាតិខ្មែរបានសម្រក់ដោយសារស្រឡាញ់ជាតិ ខំការពារជាតិយ៉ាងមានៈ ឲ្យបានគង់វង្ស ចំពោះការជិះជាន់របស់ពួកអាណានិគមនិយម ដែលពុំញញើតដៃនឹងសម្លាប់បំផ្លាញបំបាត់ក្រុមបញ្ញវន្តយើង ។

លោកអាចារ្យ ហែម-ចៀវ បានស្លាប់ចោលឆ្អឹងនៅក្នុងគុកឯកោះត្រឡាច ដែលជាមណ្ឌលដាក់ទណ្ឌកម្ម ធ្វើឲ្យទារុណកម្មដល់ពួកបះបោរនៅឥណ្ឌូចិនដែលហ៊ានតស៊ូប្រឆាំងនឹងអំណាចផ្ដាច់ការរបស់អាណានិគមនិយមបារាំង ។ ក្រៅពីឈ្មោះលោក ហែម-ចៀវ គេអាចរៀបរាប់រាយឈ្មោះអ្នកតស៊ូខ្មែរដ៏ច្រើនទៀត ដែលបានទទួលរងគ្រោះស្លាប់បាត់បង់ជីវិតដោយសារស្នាដៃបារាំងមាន ក្រឡាហោមគង់, អាចារ្យស្វា, ពោកំបោរ ជាដើម និងការឃុបឃិតក្បត់ជាតិរបស់ខ្មែរខ្លះ ដែលបានលក់ខ្លួនប្ដូរផ្ដាច់ផ្ដាប់ចិត្តចៅហ្វាយបរទេស ។

ក្នុងសម័យរាជនិយមសក្តិភូមិ អ្នកកាន់អំណាចតែភ័យព្រួយបារម្ភចំពោះគំនិតបដិវត្តន៍ ។ ហេតុនេះជីវប្រវត្តិនៃអ្នកតស៊ូដើម្បីជាតិ មានការប្រឆាំងនឹងពួកអាណា

និគមនិយមជាដើម បានត្រូវគេបំភ្លេចចោលបំផ្លាញស្នាដៃបំបាត់ភស្តុតាង ហើយខំបំប៉នទំព័រប្រវត្តិសាស្ត្រឲ្យលើកដំកើងវណ្ណៈ ដែលបានទទួលបុព្វសិទ្ធិក្នុងការជិះជាន់ ប្រវ័ញ្ចពីជិតក្ដីឆ្ងាយក្ដី លើប្រជារាស្ត្រតែប៉ុណ្ណោះ ។ ហេតុនេះទៀត អក្សរសិល្ប៍ជាតិយើង ដែលបានបំភ្លេចចោលសូន្យសុងនូវដំណាក់ឈាមនៃអ្នកដែលបានបូជាជីវិតជូនជាតិ គួរតែបំផុសរឿងបដិវត្តិន៍របស់អ្នកស្នេហាជាតិ ឲ្យបានពិស្ដារឡើងវិញ ។

ក្នុងកាលៈទេសៈដ៏លំបាក ដែលខ្មែរយើងត្រូវពង្រឹងមនសិការជាតិឲ្យកាន់តែបានរឹងប៉ឹងជាអតិមរមា ដើម្បីអាយុជីវិតជាតិ ហើយដែលខ្មែរយើងកំពុងលើកដំកើងគំនិតបដិវត្តន៍ស្នេហាជាតិនោះ ក៏គួរតែយើងចេះរួបរួមគ្នា ឬមួយចេះចែកផ្លូវគ្នាដើរ តាមលទ្ធិប្រជាធិបតេយ្យយ៉ាងច្បាស់លាស់មួយ ( La vraie démocratie est de savoir se diviser ) ។ បើពុំដូច្នោះទេ ការបំផុសមនសិការជាតិ គ្រាន់តែបណ្ដោយឲ្យប្រវត្តិសាស្ត្រថ្មីសើចចំអក ដើម្បីបង្កើតឧណ្ហកម្មដល់យើងថែមទៀតប៉ុណ្ណោះទេ ។ ហើយគំនិតរបស់លោកអាចារ្យ ហែម-ចៀវ ដែលទើបនឹង «រស់» ឡើងវិញនេះក្ដី ក៏នឹងត្រូវសាបសូន្យទៅវិញមិនខាន ។

**នគរវត្ត**
ចេញថ្ងៃទី៥ កក្កដា ១៩៧២

❑

# អាចារ្យ ហែម-ចៀវ

លោកប៊ុណ្ណចន្ទ-ម៉ុល បានធ្វើសម្ភាសន៍ក្នុងទូរទស្សន៍ខ្មែរថ្ងៃទី៧ ខែនេះ អំពីអដ្ឋិធាតុលោកអាចារ្យ ហែម-ចៀវ ដែលលោកបានទៅគាស់យកមកពីកោះត្រឡាច ដើម្បីយកមកធ្វើបុណ្យជាផ្លូវការនៅថ្ងៃមុខ ។ លោកពន្យល់ឲ្យយើងរាល់គ្នាគិតឃើញថា ទោះលោកស្លាប់ទៅជាង៣០ឆ្នាំហើយ គង់តែជាតិមិនភ្លេចគុណលោកអាចារ្យ ហែម-ចៀវ ដែលលោកបានធ្វើចំពោះជាតិ ។ តាមលោកប៊ុណ្ណចន្ទ-ម៉ុល ហើយតាមយើងបានដឹងពុខ្លះៗមក លោកអាចារ្យ ហែម-ចៀវច្បាស់ជាអ្នកភ្ញាក់រឭកទីមួយចំពោះវាសនាជាតិមែន ។ យើងជាពលរដ្ឋសាធារណរដ្ឋខ្មែរមានចិត្តជាខ្មែរទាំងអស់គ្នា គួរចាំឲ្យច្បាស់នូវពាក្យលោកប៊ុណ្ណចន្ទ-ម៉ុល ដែលលោកបានរំលឹកថា ស្រុកណាក៏ដោយ គេតែងមានមនុស្សជាគំរូ ដែលត្រូវយកឆាយាល័ក្ខណ៍មកទុក

ផ្ទះ ជាគ្រឿងសក្ការបូជា ។

នៅស្រុកក្លិង្គគេទុក គន្ធី ជាមនុស្សទី១ ដែលពលរដ្ឋគេមានរូបទុកជាវត្ថុសក្ការបូជាគ្រប់ៗគ្នា គេយកនារីម្នាក់គឺនាង សានដាក ដែលរាស្ត្រនៅស្រុកបារាំង គេទទួលស្គាល់ជាព្រះមួយរូបដែរ ( Sainte Jeann D'Arc ) នៅស្រុកឯទៀតក៏មានមនុស្សដែលស្លាប់ទៅយូរហើយ ដែលរដ្ឋគេមិនភ្លេចសងគុណាឡើយ ។

តែយើងគួរកត់សំគាល់ថា មនុស្សដែលគេគួរគោរព គឺច្រើនតែមនុស្សស្លាប់យូរទៅហើយៗ ដែលគ្មាននរណាអាច ប្រកែកបានថាមិនមែនជាអ្នកស្នេហាជាតិឡើយ ។

ស្តេចសីហនុបានបើកឆាកមុនគេឲ្យគេគោរពទាំងអស់ យើងបានឃើញហើយថា ការគោរពនេះបានធ្វើទៅក្នុងការបង្ខិតបង្ខំ ហើយដែលស្តេចនេះដើរខុសផ្លូវយកសត្រូវធ្វើជាមិត្ត យកមិត្តធ្វើជាសត្រូវ យើងរាល់គ្នាមិនត្រឹមតែលែងគោរពយើងបានទាំងកាត់ទោសស្តេចនេះ ថាជាស្តេចក្បត់ជាតិ ត្រូវមានទោសប្រហារជីវិតផង ។

**ស. ស.**
ស្រង់ចេញពីដារពត៌មានសង្រ្គោះជាតិ
ថ្ងៃទី១០ កក្កដា ១៩៧២

អត្ថបទទាំងពីរខាងលើនេះសឲ្យឃើញថា ព្រះអាចារ្យ ហែម-ចៀវ មិនមែនជាមនុស្សធម្មតាទេ គឺលោកពិតជាបានបំពេញមហាពលិកម្មដ៏ប្រសើរ ជូនជាតិ សាសនា ដ៏ឥតប្រកែកបានឡើយ ។ យើងមានការសោកស្តាយណាស់ ដោយមិនបានចុះអត្ថបទសំខាន់ៗនៃសារពត៌មានដទៃទៀត ព្រោះកុំឲ្យក្រាស់ពេក ។

# ប្រកាសនីយប័ត្រ រដ្ឋបុរសជាតិ

បានឃើញ សេចក្ដីសំរេចរបស់គណៈរដ្ឋមន្ត្រី សម័យប្រជុំនាថ្ងៃទី ២២ មីនា គ.ស. ១៩៧២ ស្ដីពីការទទួលស្គាល់ និងការផ្ទេរធាតុលោកអាចារ្យ ហែម-ចៀវ មកពីកោះត្រឡាច,

បានឃើញ សេចក្ដីសំរេចរបស់គណៈរដ្ឋមន្ត្រី សម័យប្រជុំនាថ្ងៃទី ១៩ កក្កដា គ.ស. ១៩៧២ តម្កល់តម្កើងឋានៈលោកអាចារ្យ ហែម-ចៀវ ជារដ្ឋបុរសជាតិ ក្នុងបច្ឆាមរណៈ,

## ប្រធានាធិបតី នៃ សាធារណរដ្ឋខ្មែរ ប្រកាសថា :

បានទទួលស្គាល់នូវអំពើល្អទាំងឡាយ របស់លោកគ្រូអាចារ្យ ហែម-ចៀវ ដែលបានធ្វើជូនប្រជាជាតិខ្មែរ គឺសកម្មភាពមុះមុតអង់អាច កាលពីរវាង គ.ស. ១៩៤២ ដើម្បីដាស់សតិកូនខ្មែរឲ្យប្រឆាំង និងរើបម្រះចេញពីនឹមអាណានិគមនិយមបរទេស ។

ប្រជាជាតិខ្មែរ សូមតម្កល់លោកគ្រូអាចារ្យ ហែម-ចៀវ ទុកជារដ្ឋបុរសជាតិ និងជាគំរូដ៏ឧត្តម សំរាប់កុលបុត្តខ្មែរទូទៅ ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២០ កក្កដា គ.ស. ១៩៧២

**សេនាប្រមុខ លន់-នល់**

# ស្រណោះអាចារ្យ ហែម-ចៀវ

និពន្ធដោយសិស្ស ពៅ-សុទ្ធី
« ជូនដល់អ្នកស្នេហាជាតិខ្មែរគ្រប់រូប »

ផ្ទើម សម្លេងកប៉ាល់ទូន ! ទូន !.....

១- សម្រែកនាវាលាកំពង់ផែ ទៅមុខឥតបែរដឹកនាំជនខ្មែរអ្នកស្នេហាជាតិ
សែនចុកឈាមណាស់ ឱវាចង្រៀត លាអស់ផៅញាតិ ឃ្លាតទាំងសាសនា ។

២- មុខគួរសង្វេគក្រោមមេឃបណ៍ប្រាក់ ដៃជាប់ច្រវាក់ជើងប្រឹងទធាក់សែន
វេទនា ខំផ្ចង់អញ្ជលីស្រដីឡើងថា ឲ្យជាតិខេមរា នាំគ្នាភ្ញាក់ឡើង ។

បន្ទរ- ឱ ! សំដីចុងក្រោយដង្ហោយហៅខ្មែរ សូមជួយកែប្រែជាតិឲ្យថ្កើង
ធ្វើម្ដេចរូបលោកបានជាជ្រុលជើង ទុកឲ្យរូបយើងសោកស្ដាយគ្រប់គ្នា ។

៣- ហែម-ចៀវ កំសត់ព្រាត់រូបបាត់ទៅ តែកេរ្តិ៍ឈ្មោះនៅរន្ទឺក្រអៅពេញលោកា
វង្គបុរសនៃជាតិខេមរា បូជាកាយាជូនប្រទេសជាតិ ។

ចម្រៀងនេះមិត្តសិល្បករណាក៏អាចយកទៅច្រៀងបានដែរ
ឲ្យតែរក្សាឈ្មោះអ្នកតែង

❑

# ឱ! កោះត្រឡាច

បទភ្លេង-ទំនុកច្រៀង
យ៉ង់-ឈាង

ច្រៀងដោយ
សំនៀង-ឫទ្ធី

ផ្ដើម- ឱ ! ទឹកដីព្រៃព្រឹក្សានាកោះត្រឡាច ខ្ញុំសូមផ្ញើព្រះអដ្ឋិធាតុលោកគ្រូអាចារ្យហែម-ចៀវ និងខ្មែរស្នេហាជាតិឯទៀតផង...

១- ឱ ! កោះត្រឡាច គួរឲ្យខ្លាច ហើយរន្ធត់ ដែលបានរំលត់ វិញ្ញាណក្ខន្ធអាចារ្យហែម-ចៀវ ចារឹកដោយឈាម លើផែនដី ស្រែកហ៊ោរកញ្ជៀវខំអំពាវនាវ ហៅរកកូនខ្មែរ អ្នកបដិវត្តន៍ ។

២- កោះត្រឡាចអើយ ខ្ញុំឮហើយៗសច្ចា ការពារសាសនាបន្តការណ៍លុះត្រាជោគជ័យ ទឹកចិត្តកូនខ្មែរនាសម័យ សាធារណរដ្ឋ មិនដែលភ្លាំងភ្លាត់ភ្លេចបុព្វបុរសឧត្ដមអតីតឡើយ ។

អំណោយពីលោកយ៉ង់-ឈាង អ្នកនិពន្ធបទភ្លេងនិងទំនុកច្រៀង
បដិវត្តន៍ដ៏ល្បីល្បាញ ក្នុងសាធារណរដ្ឋខ្មែរ